**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**


# សារណាបញ្ចប់ការសិក្សា

# ការអភិវឌ្ឍវិស័យដឹកជញ្ជូនផ្លូវដែកនៅក្នុងប្រទេសកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩


| | |
|---|---|
| គាត់តែងឡើងដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ៖ **ស៊ឹម សុវណ្ណពិសិដ្ឋ** | បណ្ឌិត **ខ៉ាន់ ស៊ុនដេត** |
| **សឿនសាយ័ន្ត ថវិកា** | |
| ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍ | ឆ្នាំចូលសិក្សា ២០១៥ |
| ជំនាន់ទី៣ | ឆ្នាំសរសេរសារណា ២០១៩ |

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ ស៊ឹម សុវណ្ណពិសិដ្ឋ និង សឿនសាយ័ន្ត ថវិកា ជានិស្សិតបរិញ្ញាបត្រសេដ្ឋកិច្ចជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ ជំនាន់ទី ៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ក្នុងការសរសេរសារណាបញ្ចប់ការសិក្សាលើប្រធានបទ "ការអភិវឌ្ឍវិស័យដឹកជញ្ជូនផ្លូវដែកនៅក្នុងប្រទេសកម្ពុជា" យើងខ្ញុំសូមធ្វើការគោរពជូន និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនដូចតទៅៈ

ជាបឋមយើងខ្ញុំសូមសម្ដែងនូវការដឹងគុណ និងការគោរពដ៏ខ្ពង់ខ្ពស់បំផុតចំពោះ លោកឪពុក អ្នកម្ដាយដែលមានគុណដ៏ធំធេងហើយលោកទាំងពីរបានផ្ដល់កំណើត ចិញ្ចឹមបីបាច់ថែរក្សាព្រមទាំងអប់រំទូន្មានប្រៀនប្រដៅ។ អ្វីដែលពិសេសនោះគឺលោកបានខិតខំប្រឹងប្រែងទាំងកម្លាំងកាយកម្លាំងចិត្ត និងធនធានទំនុកបម្រុងការសិក្សាតាំងពីថ្នាក់បឋមសិក្សារហូតដល់ថ្នាក់បរិញ្ញាបត្រនេះ។

សូមថ្លែងអំណរគុណដល់លោកគ្រូ សាស្ត្រាចារ្យបណ្ឌិត ង៉ាន់ ស៊ុនដេត ដែលបានជួយជ្រោមជ្រែង ដឹកនាំ ដាស់តឿន ហើយបានកែតម្រូវនូវកំហុសខុសឆ្គងដែលមាននៅក្នុងសារណានេះចាប់តាំងពីចំណុចចាប់ផ្ដើមរហូតទទួលបានជោគជ័យ ទោះបីជាមានពេលវេលាតិចតួចស្ដួចស្ដើងយ៉ាងណាក៏ដោយ។

សូមថ្លែងអំណរគុណដល់លោក អ៊ុក អ៊ួ ប្រធាននាយកដ្ឋានផ្លូវដែក និងលោក ចាប ម៉ូលី ប្រធានការិយាល័យបុគ្គលិក និងធនធានមនុស្សនៃនាយកដ្ឋានផ្លូវដែក ព្រមទាំងមន្ត្រីរាជការទាំងអស់នៃនាយកដ្ឋានផ្លូវដែក ក្រសួងសាធារណការ និងដឹកជញ្ជូន ដែលលោកបានផ្ដល់នូវការស្វាគមន៍ចំពោះការចុះស្រាវជ្រាវឯកសារ ដែលលោកបានផ្ដល់ឯកសារមួយចំនួនដែលទាក់ទងនិងផ្លូវដែកនៅកម្ពុជាដល់យើងខ្ញុំ។

ជាមួយគ្នានេះដែរ យើងខ្ញុំសូមថ្លែងអំណរគុណដល់សាស្ត្រាចារ្យទាំងអស់ដែលបង្រៀននៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាពិសេសសូមអរគុណដល់សាស្ត្រាចារ្យដែលបានបង្ហាត់បង្រៀនយើងខ្ញុំដែលជាការរួមចំណែកជំរុញការសិក្សាអស់រយៈពេល៤ឆ្នាំកន្លងមកនេះ ព្រមទាំងមិត្តរួមថ្នាក់ទាំងអស់ដែលបានសិក្សាជាមួយគ្នាកន្លងមក។

# អារម្ភកថា

បន្ទាប់ពីបានសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចលើមុខជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍រយៈពេល៤ឆ្នាំ ចំពោះសារណានេះជាការស្រាវជ្រាវកម្រិតបឋមក្នុងរយៈពេលកំណត់មួយ ហើយក៏ជាលទ្ធផលចុងក្រោយ និងជាចំណេះដឹងដែលបានសិក្សាអស់រយៈពេល ៤ឆ្នាំនៃថ្នាក់បរិញ្ញាបត្រជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍។

សារណានេះ គឺសិក្សាស្រាវជ្រាវលើប្រធានបទ "ការអភិវឌ្ឍវិស័យដឹកជញ្ជូនផ្លូវដែកនៅក្នុងប្រទេសកម្ពុជា" គឺមានគោលបំណងក្នុងការពង្រីកចំណេះដឹងទៅលើវិស័យដឹកជញ្ជូនតាមផ្លូវដែកដោយយោងទៅតាមឯកសារមួយចំនួនបានបង្ហាញថា វិស័យដឹកជញ្ជូនតាមផ្លូវដែកកំពុងដើបមុខឡើងវិញនៅក្នុងប្រទេសកម្ពុជា។ ការស្រាវជ្រាវនេះ និងផ្តល់ចំណេះដឹងទាក់ទងនឹងប្រវត្តិផ្លូវដែកកម្ពុជា ការជួសជុលផ្លូវដែកកន្លងមក ស្ថានភាពប្រតិបត្តិការរបស់រថភ្លើងនៅកម្ពុជា គោលនយោបាយរបស់រដ្ឋាភិបាលក្នុងការអភិវឌ្ឍវិស័យដឹកជញ្ជូនតាមផ្លូវដែក ជាងនេះទៅទៀតការសិក្សាស្រាវជ្រាវនេះក៏ធ្វើការវិភាគទៅលើវឌ្ឍនភាពចុងក្រោយនៅលើវិស័យដឹកជញ្ជូនផ្លូវដែកក្រោយពេលដែលរដ្ឋាភិបាលបានប្រគល់ឲ្យក្រុមហ៊ុនឯកជនជាអ្នកគ្រប់គ្រង បន្ថែមពីលើនេះទៅទៀតយើងនឹងវិភាគទៅលើចំណុចវិជ្ជមាន និងចំណុចអវិជ្ជមានក្នុងការធ្វើប្រតិបត្តិការផ្លូវដែកនៅក្នុងប្រទេសកម្ពុជា។

ជាចុងក្រោយ យើងខ្ញុំសូមថ្លែងអំណរគុណដល់ ឯកឧត្តម លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអានទាំងឡាយ ដែលមានចំណាប់អារម្មណ៍ និងចំណាយពេលដ៏មានតម្លៃក្នុងការអានកិច្ចការស្រាវជ្រាវរបស់យើងខ្ញុំ។ ទោះជាយ៉ាងណាក៏ដោយ កិច្ចការស្រាវជាវនេះពិតជាមានកង្វះខាតនិងកំហុសឆ្គងណាមួយដោយជៀសពុំផុត ដោយការយល់ដឹងនៅមានកម្រិត ការខ្វះខាតបទពិសោធន៍ក្នុងការអនុវត្តជាក់ស្តែង រួមនិងឯកសារមានកម្រិត ព្រមទាំងថេរវេលាមានកំណត់។ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាឯកសារនេះពិតជាផ្តល់អត្ថប្រយោជន៍ និងខ្លឹមសារសំខាន់ៗ ជាចំណេះដឹង និងជាពិសេសសម្រាប់និស្សិតណាដែលចង់ធ្វើការស្រាវជ្រាវលើប្រធានបទដែលទាក់ទងនឹងផ្លូវដែក ដើម្បីទុកជាទុនក្នុងការស្រាវជ្រាវបន្តទៀតផងដែរ។ ដូចនេះយើងខ្ញុំរីករាយស្វាគមន៍រាល់មតិរិះគន់ដើម្បីស្តាបនាពីសំណាក់ ឯកឧត្តម លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តនិស្សិតដើម្បីឲ្យការសិក្សាស្រាវជ្រាវនេះកាន់តែល្អប្រសើរជាមុន។

# មាតិកា

**ទំព័រ**

បញ្ជីអក្សរកាត់.....V
បញ្ជីតារាង.....Vi
បញ្ជីក្រាហ្វិក.....Vii

## សេចក្តីផ្តើម

១. លំនាំបញ្ហា.....១
២. គោលបំណងនៃការស្រាវជ្រាវ.....១
៣. ចំណោទបញ្ហា.....២
៤. សារៈសំខាន់នៃការស្រាវជ្រាវ.....២
៥. ទំហំ និងដែនកំណត់.....២
៦. វិធីសាស្រ្តក្នុងការស្រាវជ្រាវ.....២
៧. រចនាសម្ព័ន្ធ.....២

## ជំពូកទី១

## រំលឹកទ្រឹស្តី

១. ១ ទ្រឹស្តីនៃការដឹកជញ្ជូនតាមរយៈផ្លូវដែក.....៤
១.២ ប្រវត្តិនៃផ្លូវដែក.....៤
១.៣ ប្រភេទនៃផ្លូវដែក.....៦
១.៤ អត្ថប្រយោជន៍នៃការដឹកជញ្ជូនតាមរយៈផ្លូវដែក.....៦
១.៥ ការរីកចម្រើននៃផ្លូវដែកនៅបរទេស.....៨
១.៥.១ ករណីសិក្សាប្រទេសឥណ្ឌូនេស៊ី.....៨
១.៥.២ ករណីសិក្សាប្រទេសថៃ.....១០
១.៥.៣ ករណីសិក្សាប្រទេសម៉ាឡេស៊ី.....១២

## ជំពូកទី២

## ស្ថានភាពទូទៅនៃផ្លូវដែកកម្ពុជា

២.១ ប្រវត្តិនៃការកកើតផ្លូវដែកនៅកម្ពុជា.....១៤
២.១.១ ប្រវត្តិផ្លូវដែកកម្ពុជា.....១៤

២.១.២ ផ្លូវដែកមុនឆ្នាំ ១៩៧០ ........ ១៥
២.១.៣ ផ្លូវដែកចាប់ពីឆ្នាំ ១៩៧០-១៩៧៩ ........ ១៦
២.១.៤ ផ្លូវដែកចាប់ពីឆ្នាំ ១៩៨១-១៩៩៨ ........ ១៦
២.១.៥ ផ្លូវដែកចាប់ពីឆ្នាំ ១៩៩៨-២០០៥ ........ ១៨
២.២ ការជួសជុសឡើងវិញ ........ ២២
២.២.១ ការជួសជុលអំឡុងឆ្នាំ ១៩៩៣-១៩៩៥ ........ ២២
២.២.២ ការជួសជុលអំឡុងឆ្នាំ ២០០១-២០០៣ ........ ២២
២.២.៣ ការជួសជុលអំឡុងឆ្នាំ ២០០៦-២០១០ ........ ២៣
២.២.៤ ការជួសជុលអំឡុងឆ្នាំ ២០០៩-២០១៤ ........ ២៤
២.៣ ស្ថានភាពផ្លូវដែក និងការដឹកជញ្ជូនបច្ចុប្បន្នរបស់ផ្លូវដែកកម្ពុជា ........ ២៤
២.៣.១ ផ្លូវដែកភាគខាងត្បូង (ភ្នំពេញ-ព្រះសីហនុ) ........ ២៥
២.៣.១.១ សេវាដឹកអ្នកដំណើរភាគខាងត្បូង ........ ២៥
២.៣.១.២ តម្លៃធ្វើយាន្តជំនិះ ........ ២៦
២.៣.១.៣ កាលវិភាគរថភ្លើងចេញដំណើរ ........ ២៦
២.៣.២ ផ្លូវដែកភាគខាងជើង (ភ្នំពេញ-ប៉ោយប៉ែត) ........ ២៧
២.៣.២.២ តម្លៃធ្វើយាន្តជំនិះ ........ ៣០
២.៣.៣ ទិន្នន័យនៃការធ្វើប្រតិបត្តិការ ២០១៨ ........ ៣០
២.៤ ផែនការមេនិងយុទ្ធសាស្រ្តគោលការណ៍នៃការអភិវឌ្ឍន៍ផ្លូវដែក ........ ៣២
២.៤.១ ការអភិវឌ្ឍក្នុងពេលខ្លី ២០១៤-២០២០ ........ ៣៣
២.៤.២ ការអភិវឌ្ឍក្នុងពេលមធ្យម ២០២១-២០៣០ ........ ៣៣
២.៤.៣ ការអភិវឌ្ឍក្នុងពេលវែងបន្ទាប់ពីឆ្នាំ ២០៣០ ........ ៣៣
២.៤.៣.១ ផ្លូវដែកល្បឿនលឿន ........ ៣៣
២.៤.៣.២ តំបន់សក្តានុពល ........ ៣៤

២.៤.៣.៣ ផ្លូវឧស្សាហកម្ម ........................................................................................... ៣៤

២.៤.៣.៤ ផ្លូវដែកទៅកាន់ព្រលានយន្តហោះ និងកំពង់ផែ ................................................ ៣៥

២.៤.៤ ស្តង់ដាផ្លូវដែក ......................................................................................................... ៣៥

២.៤.៥ បញ្ហាប្រឈមចម្បងសម្រាប់គម្រោងផែនការមេ ........................................................... ៣៦

២.៤.៦ ដំណោះស្រាយសម្រាប់គម្រោងផែនការមេ .................................................................. ៣៦

២.៥ អត្ថប្រយោជន៍សេដ្ឋកិច្ចពីវិស័យដឹកជញ្ជូនផ្លូវដែកក្រោយពីសម្រេចផែនការមេ... ៣៧

២.៥.១ ការប៉ាន់ប្រមាណនៃការសន្សំការប្រើប្រាស់ប្រេង ....................................................... ៣៨

២.៥.២ ការប៉ាន់ប្រមាណនៃការសន្សំក្នុងចំណាយលើការថែទាំផ្លូវ ........................................ ៣៨

២.៥.៣ ការប៉ាន់ស្មាននៃការសន្សំពីគ្រោះថ្នាក់ចរាចរណ៍ ....................................................... ៣៩

## ជំពូកទី៣

## ការវិភាគវិស័យដឹកជញ្ជូនតាមផ្លូវដែក

៣.១ វិភាគទៅលើទិន្នន័យដឹកជញ្ជូនទំនិញ និងអ្នកដំណើរតាមផ្លូវដែក ................................ ៤១

៣.១.១ វិភាគលើទិន្នន័យដឹកជញ្ជូនទំនិញ ............................................................................ ៤១

៣.១.២ វិភាគលើទិន្នន័យដឹកជញ្ជូនអ្នកដំណើរតាមផ្លូវដែក ................................................. ៤៣

៣.២ វិភាគទៅលើលទ្ធផលនៃការស្រង់មតិ ........................................................................... ៤៤

៣.២.១ អ្នកដំណើរតាមរថភ្លើង ............................................................................................ ៤៤

៣.២.២ មុខរបររបស់អ្នកដំណើរ ........................................................................................... ៤៥

៣.២.៣ ការធ្វើដំណើរការតាមរដូវកាល ................................................................................. ៤៥

៣.២.៤ មូលហេតុដែលអ្នកដំណើរជ្រើសរើសយកការជិះរថភ្លើង ............................................ ៤៦

៣.២.៥ មូលហេតុដែលអ្នកដំណើរមិនជ្រើសរើសយកការជិះរថភ្លើង ...................................... ៤៧

៣.២.៦ ការវិភាគលើទំនាក់ទំនង ......................................................................................... ៤៨

៣.៣ លទ្ធផលនៃការស្រាវជ្រាវ .......................................................................................... ៥៣

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន ..................................................................................................... ៥៥

២. អនុសាសន៍ ........................................................................................................................ ៥៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

RRC ៖ Royal Railway Cambodia ក្រុមហ៊ុន រ៉ូយ៉ាល់ រេលវេ កម្ពុជា

PT KAI ៖ PT Kereta Api Indonesia ក្រុមហ៊ុនធ្វើប្រតិបត្តិការដឹកជញ្ជូននៅប្រទេសឥណ្ឌូនេស៊ី

UNDP ៖ United Nation Development Programme កម្មវិធីអភិវឌ្ឍរបស់អង្គការសហប្រជាជាតិ

ADB ៖ Asia Development Bank ធនាគារអភិវឌ្ឍន៍អាស៊ី

WB ៖ World Bank ធនាគារពិភពលោក

OPEC ៖ The Organization of the Petroleum Exporting Countries អង្គការគ្រប់គ្រងការនាំចេញប្រេង

AKP ៖ Agence Kampuchea Press ទីភ្នាក់ងារសារព័ត៌មានកម្ពុជា

DMU ៖ Diesel Multiple Unit ក្បាលរថភ្លើងប្រើម៉ាស៊ុត

KOICA ៖ Korea International Coopertation Agency ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ

JICA ៖ Japan International Cooperation Agency ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន

# បញ្ជីតារាង

**ទំព័រ**


តារាងទី១ ៖ បង្ហាញពីចំនួន និងអាយុកាលរបស់ក្បាលម៉ាស៊ីន និងទូរថភ្លើងថៃ ................ ១១
តារាងទី២ ៖ បង្ហាញពីប្រវត្តិនៃការសាងសង់ផ្លូវដែកខ្សែខាងជើង ..................................... ១៤
តារាងទី៣ ៖ បង្ហាញពីប្រវត្តិនៃការសាងសង់ផ្លូវដែកខ្សែខាងត្បូង ..................................... ១៥
តារាងទី៤ ៖ បង្ហាញពីទិន្នន័យនៃការដឹកជញ្ជូនតាមផ្លូវដែក (ឆ្នាំ ១៩៨១ ដល់ ១៩៩៨) .......១៧
តារាងទី៥ ៖ បង្ហាញពីឈ្មោះក្រុមហ៊ុន និងប្រភេទដែលប្រើប្រាស់ការដឹកជញ្ជូនតាមផ្លូវដែក ១៩
តារាងទី៦ ៖ បង្ហាញពីទំហំនៃការដឹកជញ្ជូនខ្សែខាងជើង និងខាងត្បូង (១៩៩៨-២០០៥)..... ២០
តារាងទី៧ ៖ បង្ហាញពីតម្លៃសំបុត្រតាមទិសដៅនៅខ្សែខាងត្បូង....................................... ២៥
តារាងទី៨ ៖ បង្ហាញពីតម្លៃដឹកយានជំនិះតាមរថភ្លើងនៅខ្សែខាងត្បូង ............................... ២៦
តារាងទី៩ ៖ បង្ហាញពីថ្ងៃ និងម៉ោងចេញដំណើរនៅខ្សែខាងត្បូង....................................... ២៦
តារាងទី១០ ៖ បង្ហាញពីទិសដៅចេញដំណើរនៅខ្សែខាងជើង ............................................ ២៩
តារាងទី១១ ៖ បង្ហាញពីតម្លៃដឹកជញ្ជូនយានជំនិះនៅខ្សែខាងជើង .......................................៣០
តារាងទី១២ ៖ បង្ហាញពីទិន្នន័យទាក់ទងនិងផ្លូវដែកកម្ពុជា..................................................៣១
តារាងទី១៣ ៖ បង្ហាញពីទិន្នន័យស្តង់ដាផ្លូវដែកកម្ពុជា .......................................................៣៥
តារាងទី១៤ ៖ បង្ហាញពីដំណោះស្រាយគោលដៅ និងយុទ្ធសាស្ត្រនៃផែនការមេ..................៣៦
តារាងទី១៥ ៖ បង្ហាញពីគ្រោះថ្នាក់ និងការខាតបង់ ..........................................................៣៩
តារាងទី១៦ ៖ បង្ហាញពីចំនួននៃការខាតបង់ពីគ្រោះថ្នាក់ចរាចរណ៍...................................... ៤០
តារាងទី១៧ ៖ បង្ហាញពីទំហំនៃការដឹកជញ្ជូនសរុបតាមឆ្នាំនីមួយៗ (២០១០-២០១៨)............ ៤១
តារាងទី១៨ ៖ បង្ហាញពីទំនាក់ទំនងរវាងភេទ និងមូលហេតុនៃការជិះរថភ្លើង ....................... ៤៨
តារាងទី១៩ ៖ បង្ហាញពីទំនាក់ទំនងរវាងអាយុ និងមូលហេតុនៃការជិះរថភ្លើង...................... ៤៩
តារាងទី២០ ៖ បង្ហាញពីទំនាក់ទំនងរវាងមុខរបរ និងមូលហេតុនៃការជិះរថភ្លើង ................... ៥២

# បញ្ជីក្រាហ្វិក

**ទំព័រ**

ក្រាហ្វិកទី ១ ៖ បង្ហាញពីទំហំនៃការដឹកជញ្ជូន (១៩៨១-១៩៩៨)........................................ ១៨
ក្រាហ្វិកទី ២ ៖ បង្ហាញពីទំហំនៃការដឹកជញ្ជូន (១៩៩៨-២០០៥)........................................២០
ក្រាហ្វិកទី ៣ ៖ បង្ហាញពីទិន្នន័យនៃការដឹកជញ្ជូនសរុបតាមឆ្នាំនីមួយៗ (២០១០-២០១៨)..... ៤២
ក្រាហ្វិកទី ៤ ៖ បង្ហាញពីទិន្នន័យអ្នកដំណើរតាមរថភ្លើងសរុប (២០១៧ និង ២០១៨) ...........៤៣
ក្រាហ្វិកទី ៥ ៖ បង្ហាញពីទិន្នន័យអាយុអ្នកដំណើរតាមរថភ្លើង ............................................ ៤៤
ក្រាហ្វិកទី ៦ ៖ បង្ហាញពីទិន្នន័យមុខរបរអ្នកដំណើរតាមរថភ្លើង .......................................... ៤៥
ក្រាហ្វិកទី ៧ ៖ បង្ហាញពីទិន្នន័យរដូវកាលដែលអ្នកដំណើរចូលចិត្តជិះរថភ្លើង ..................... ៤៦
ក្រាហ្វិកទី ៨ ៖ បង្ហាញពីទិន្នន័យមូលហេតុដែលអ្នកដំណើរជ្រើសរើសជិះរថភ្លើង ................ ៤៦
ក្រាហ្វិកទី ៩ ៖ បង្ហាញពីទិន្នន័យមូលហេតុដែលអ្នកដំណើរមិនជ្រើសរើសជិះរថភ្លើង...........៤៧
ក្រាហ្វិកទី ១០ ៖ បង្ហាញពីទំនាក់ទំនងភេទ និងមូលហេតុនៃការជិះរថភ្លើង .......................... ៤៩
ក្រាហ្វិកទី ១១ ៖ បង្ហាញពីទំនាក់ទំនងអាយុ និងមូលហេតុនៃការជិះរថភ្លើង.......................... ៥១
ក្រាហ្វិកទី ១២ ៖ បង្ហាញពីទំនាក់ទំនងមុខរបរ និងមូលហេតុនៃការជិះរថភ្លើង.......................៥៣

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ប្រទេសកម្ពុជាបច្ចុប្បន្នជាប្រទេសកំពុងអភិវឌ្ឍន៍។ សេដ្ឋកិច្ចកម្ពុជាកំពុងស្ថិតលើមាគ៌ាដ៏ជោគជ័យនៃការងើបឡើងវិញយ៉ាងខ្លាំងដោយសារតែកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល និងវិស័យឯកជន[1]។ ក្នុងឆ្នាំ ២០១៧ សេដ្ឋកិច្ចនៅតែបន្តកើនឡើងក្នុងរង្វង់ ៦,៩% ជាមួយនិងការរក្សាបានស្ថិរភាពសេដ្ឋកិច្ច និងហរិញ្ញវត្ថុរឹងមាំ[2]។ កំណើនសេដ្ឋកិច្ចនេះដោយសារការអនុវត្តគោលនយោបាយសេដ្ឋកិច្ច និងហរិញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ព្រមទាំងវឌ្ឍនភាពនៃការធ្វើកំណែទម្រង់ស៊ីជម្រៅក្នុងស្រុកដែលបានរួមចំណែកគាំទ្រការរីកចម្រើនពីវិស័យសេដ្ឋកិច្ចចម្បងៗរបស់កម្ពុជា។

ក្នុងន័យនេះ វិស័យដឹកជញ្ជូនក៏ជាវិស័យដ៏សំខាន់មួយដែរ ក្នុងការជំរុញសេដ្ឋកិច្ចឲ្យរីកចម្រើនពោលគឺ វិស័យដឹកជញ្ជូនបានក្លាយជាមុខព្រួញសំខាន់របស់រដ្ឋាភិបាល ដោយវិស័យនេះត្រូវបានដាក់បញ្ចូលជាវិស័យអាទិភាពទាំង ៤ របស់រដ្ឋាភិបាលដែលមានដូចជាផ្លូវ, ទឹក, ភ្លើង និងមនុស្ស ដោយសព្វថ្ងៃនេះវិស័យដឹកជញ្ជូនបែងចែកជា ៣ធំៗគឺ ការដឹកជញ្ជូនតាមផ្លូវគោក, ផ្លូវទឹក ផ្លូវអាកាសសម្រាប់ការធ្វើដំណើរ និងការដឹកជញ្ជូនទំនិញផ្សេងៗទាំងក្នុងប្រទេស និងក្រៅប្រទេស[3]។ ក្នុងនោះការធ្វើដំណើរ និងដឹកជញ្ជូនតាមផ្លូវដែកក៏ជាផ្នែកមួយដ៏សំខាន់ផងដែរសម្រាប់បម្រើក្នុងវិស័យសេដ្ឋកិច្ច។ បច្ចុប្បន្នដោយសារការស្តារឡើងវិញនៃផ្លូវដែកទាំងពីរខ្សែត្រូវបានសាងសង់ និងជួសជុលដាក់ឲ្យប្រើប្រាស់ឡើងវិញ តាមរយៈការសហការរវាងក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រុមហ៊ុន រ៉ូយ៉ាល់ រេលវេ កម្ពុជា (RRC) ដែលផ្តល់ជម្រើសបន្ថែមមួយទៀតសម្រាប់ប្រជាជនក្នុងការធ្វើដំណើរ និងដឹកជញ្ជូន ដោយសេវាដឹកជញ្ជូនតាមផ្លូវដែកនេះមានអត្ថប្រយោជន៍សម្រាប់អ្នកដំណើរ និងទំនិញ។

## ២. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទ "ការអភិវឌ្ឍវិស័យដឹកជញ្ជូនផ្លូវដែកនៅក្នុងប្រទេសកម្ពុជា" មានបំណងដូចតទៅះ

- ស្វែងយល់ពីវិស័យផ្លូវដែកនៅក្នុងប្រទេសកម្ពុជា

[1] ម៉ៃ គុណមកក, "ស្ថានភាពសេដ្ឋកិច្ចកម្ពុជា និងការវិវឌ្ឍទៅមុខ"

[2] ធនាគារជាតិនៃកម្ពុជា, "វឌ្ឍនភាពម៉ាក្រូសេដ្ឋកិច្ច និងវិស័យធនាគារឆ្នាំ ២០១៧ និងទស្សនវិស័យឆ្នាំ ២០១៨"

[3] ឯឧបណ្ឌិត ហង់ ជួនណារ៉ុង, "សេដ្ឋកិច្ចកម្ពុជា"

- ស្វែងយល់ពីចំណុចវិជ្ជមាន និងចំណុចអវិជ្ជមានរបស់ផ្លូវដែកនាពេលបច្ចុប្បន្ន
- ស្វែងយល់ពីមតិនិងការគាំទ្ររបស់ប្រជាជន។

## ៣. ចំណោទបញ្ហា

តើការអភិវឌ្ឍវិស័យដឹកជញ្ជូនតាមរយៈផ្លូវដែកកម្ពុជានាបច្ចុប្បន្នអាចចូលរួមក្នុងការសម្រួលដល់ជីវភាពរបស់ប្រជាជនកម្ពុជាដូចម្តេចខ្លះ?

## ៤. សារៈសំខាន់នៃការស្រាវជ្រាវ

- ចែករំលែកនូវចំណេះដឹងទូទៅនៃស្ថានភាពផ្លូវដែកក្រោយពីការស្តារឡើងវិញ
- ចែករំលែកចំណេះដឹងដែលបានមកពីការស្រាវជ្រាវស្តីអំពីការចូលរួមសម្រួលដល់ជីវភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋ
- ផ្តល់ជាឯកសារសម្រាប់ការស្រាវជ្រាវក្រោយៗទៀត។

## ៥. ទំហំ និងដែនកំណត់

ការស្រាវជ្រាវនេះផ្តោតសំខាន់លើការដឹកជញ្ជូនតាមរយៈផ្លូវដែករបស់កម្ពុជារយៈពេល ៨ ឆ្នាំគឺចាប់ពីឆ្នាំ ២០១០ មកទល់ឆ្នាំ ២០១៨ ក្រោយពីក្រុមហ៊ុន រ៉ូយ៉ាល់ រេលវេ កម្ពុជា(RRC) បានទទួលសិទ្ធិវិនិយោគពីរដ្ឋាភិបាល។ ការស្រាវជ្រាវនេះបានចុះផ្ទាល់នៅនាយកដ្ឋានផ្លូវដែកនៃក្រសួងសាធារណការ និងដឹកជញ្ជូនដែលមានទីតាំងនៅមហាវិថីសហព័ន្ធរុស្ស៊ី។ បន្ថែមពីលើនេះទៀត ការស្រាវជ្រាវនេះយើងសង្កេតទៅលើតម្រូវការរបស់ប្រជាជនដែលជាអ្នកជិះរថភ្លើង ដោយធ្វើការស្រង់មតិពីអ្នកដែលជិះនៅលើរថភ្លើងផ្ទាល់តែម្តង។

## ៦. វិធីសាស្ត្រក្នុងការស្រាវជ្រាវ

ការស្រាវជ្រាវនេះចងក្រងចេញពីប្រភពឯកសារទី ១ (Primary Data) ដោយប្រើប្រាស់ការវិភាគបែបគុណវិស័យ និងបែបពណ៌នាអំពីប្រសិទ្ធភាពពីការប្រើប្រាស់រថភ្លើង និងស្វែងរកទិន្នន័យពាក់ព័ន្ធមួយចំនួនដោយប្រើប្រាស់កម្រងសំណួរចំនួន ១២សំណួរ (សំណួរជ្រើសរើសមាន ១០សំណួរ, សំណួរបើកមាន ២សំណួរ) ដែលបានធ្វើឡើងដោយការស្ទង់មតិជាមួយអ្នកដែលធ្វើដំណើរតាមរថភ្លើងចំនួន ៤០នាក់ ដើម្បីរកទិន្នន័យជាក់លាក់មួយ។ ដោយការស្ទង់មតិនេះធ្វើឡើងនៅថ្ងៃអាទិត្យ ទី១៦ ខែមិថុនា ឆ្នាំ២០១៩ រីឯទិន្នន័យដែលប្រមូលបានគឺយកមកវិភាគដោយប្រើកម្មវិធី SPSS Program។ ប្រភពឯកសារទី ២ (Secondary Data) គឺដកស្រង់ពីសៀវភៅដែលចេញពីអ្នកនិពន្ធផ្សេងៗ ទាំងភាសាខ្មែរ និងភាសាបរទេស ឯកសារចេញពីគេហទំព័រផ្សេងៗ

និងឯកសារមួយចំនួន បូករួមនឹងទិន្នន័យរបស់នាយកដ្ឋានផ្លូវដែកនៃក្រសួងសាធារណការ និងដឹកជញ្ជូន។ ក្នុងការបកស្រាយឯកសារមួយចំនួននេះត្រូវបានប្រើជាវិធីសាស្ត្របែបពណ៌នា និងពន្យល់។

## ៧. រចនាសម្ព័ន្ធ

នៅក្នុងខ្លឹមសារទាំងមូលនៃសារណានេះ យើងខ្ញុំបែងចែកជាបីជំពូក។

ជំពូកទី ១៖ ការលើកឡើងពីទ្រឹស្តីនៃការដឹកជញ្ជូនតាមរយៈផ្លូវដែក, ប្រវត្តិនៃផ្លូវដែក, ប្រភេទនៃផ្លូវដែក, អត្ថប្រយោជន៍សេដ្ឋកិច្ចតាមរយៈការដឹកជញ្ជូនតាមរយៈផ្លូវដែក, និងការរីកចម្រើននៃផ្លូវដែកនៅបរទេសដោយលើកយកប្រទេស ៣មកបង្ហាញដែលមានដូចជា ប្រទេសឥណ្ឌូនេស៊ី, ថៃ និងម៉ាឡេស៊ី។

ជំពូកទី ២៖ ស្ថានភាពទូទៅនៃផ្លូវដែកកម្ពុជា ដែលចែកជា ៥ចំណុចធំៗគឺ៖ ប្រវត្តិនៃការកកើតផ្លូវដែកនៅកម្ពុជា, ការជួសជុលឡើងវិញ, ស្ថានភាពផ្លូវដែក និងការដឹកជញ្ជូនបច្ចុប្បន្នរបស់ផ្លូវដែក, ផែនការមេ និងយុទ្ធសាស្ត្រគោលការណ៍នៃការអភិវឌ្ឍផ្លូវដែក, និងអត្ថប្រយោជន៍សេដ្ឋកិច្ចពីវិស័យដឹកជញ្ជូនផ្លូវដែកក្រោយពីសម្រេចផែនការមេ។

ជំពូកទី ៣៖ ការវិភាគលើវិស័យដឹកជញ្ជូន និងកំណើនសេដ្ឋកិច្ចដែលចែកជា ២ចំណុច៖ វិភាគទៅលើទិន្នន័យ,និងលទ្ធផលនៃការស្រាវជ្រាវ។

# ជំពូកទី១
# រំលឹកទ្រឹស្តី

## ១. ១ ទ្រឹស្តីនៃការដឹកជញ្ជូនតាមរយៈផ្លូវដែក

ការដឹកជញ្ជូនតាមរថភ្លើងនៅលើផ្លូវដែកគឺ ជាមធ្យោបាយដឹកជញ្ជូនដែលមានប្រសិទ្ធភាពបំផុតមួយក្នុងចំណោមមធ្យោបាយនៃការដឹកជញ្ជូនទាំងអស់។ ជាទូទៅរថភ្លើងត្រូវបានបំពាក់ដោយក្បាលម៉ាស៊ីនដែលកំពុងដំណើរការចរន្តអគ្គិសនី ឬប្រេងម៉ាស៊ូត។ ការដឹកជញ្ជូនផ្លូវដែកមានការរៀបចំបានល្អជាងមធ្យោបាយដឹកជញ្ជូនផ្សេងទៀតដោយសារតែវាមានផ្លូវដែលថេរ និងសេវាកម្មមានលក្ខណៈច្បាស់លាស់ និងទៀងទាត់បើប្រៀបធៀបនឹងរបៀបដឹកជញ្ជូនផ្សេងទៀត[4]។

## ១.២ ប្រវត្តិនៃផ្លូវដែក

ផ្លូវដែកបានលេចឡើងដើមទសវត្សរ៍ឆ្នាំ ១៥៥០ នៅពេលដែលប្រទេសអាល្លឺម៉ង់បានចាប់ផ្តើមដំឡើងផ្លូវដែកដើម្បីធ្វើឲ្យវាងាយស្រួលសម្រាប់រទេះរុញឆ្លងកាត់នៅតាមជនបទ។ នៅឆ្នាំ ១៧៧០ គេក៏យកឈើប្តូរចេញ ហើយជំនួសដោយដែក។ បន្ទាប់មកវិវត្តន៍ទៅជារថភ្លើងដែលធ្វើឲ្យរីករាលដាលនៅទូទាំងទ្វីបអឺរ៉ុប។ នៅឆ្នាំ ១៧៨៩ ជនជាតិអង់គ្លេសឈ្មោះ William Jessup បានរចនាក្បាលរថភ្លើងដែលមានរង្វង់កង់រត់ស្របលើផ្លូវដែក និងការរចនាដ៏សំខាន់មួយទៀតគឺ ក្បាលរថភ្លើងនោះអាចអូសទូរថភ្លើងពីក្រោយទៀតបាន។ ក្នុងឆ្នាំ ១៨០៤ ក្បាលម៉ាស៊ីនរថភ្លើងដែលដើរដោយចំហាយទឹក (ម៉ាស៊ីននោះអាចអូសដែកទម្ងន់ ១០តោន មនុស្ស ៧០នាក់ និងរទេះ ៥គ្រឿង)[5]។

ឆ្នាំ១៨២០ មានការរកឃើញថ្មីមួយដោយលោក John Birkinshaw ដោយប្តូរមកប្រើដែកថែបវិញ ដោយការដឹកជញ្ជូនផ្លូវដែកទំនើបបានចាប់ផ្តើមជាមួយជនជាតិអង់គ្លេស។ ការអភិវឌ្ឍក្បាលម៉ាស៊ីនចំហាយនៅដើមសតវត្សរ៍ទី ១៩។ ប្រព័ន្ធផ្លូវដែកនៅចក្រភពអង់គ្លេសដែលមានអាយុកាលចាស់ជាងគេនៅលើពិភពលោកដែលបង្កើតឡើងដោយលោក George Stephenson និងកូនប្រុសរបស់គាត់។ ក្បាលរថភ្លើងទី ១ គឺជាលើកដំបូងនៃក្បាលម៉ាស៊ីនរថភ្លើងដើរដោយចំហាយទឹកដើម្បីដឹកអ្នកដំណើរនៅលើខ្សែរថភ្លើងសាធារណៈនៅឆ្នាំ ១៨២៥ នៅក្រុង Stockton និងក្រុង Darlington។ លោក George ក៏បានបង្កើតខ្សែរថភ្លើងសាធារណៈជាលើកដំបូងនៅលើពិភពលោកដើម្បីប្រើក្បាលរថភ្លើងដើរដោយចំហាយទឹកដែលដំណើរការនៅខ្សែនៅទីក្រុង Liverpool និង

[4] The Economic Times, Definition of Rail Transport, https://economictimes.indiatimes.com/definition/rail-transport

[5] Mary Bellis, "The History of the Railroad", ថ្ងៃទី ២៨ កញ្ញា ឆ្នាំ២០១៨, https://www.thoughtco.com/history-of-railroad-4059935

Manchester ដែលបានបើកឲ្យដំណើរការជាផ្លូវការលើកដំបូងនៅក្នុងឆ្នាំ ១៨៣០[6]។ បន្ទាប់មកខ្សែរថភ្លើងក្រោមដីដំបូងគេរបស់ពិភពលោក ដែលមិនធ្លាប់មានពីមុនមកត្រូវបានបើកឲ្យប្រើប្រាស់ជាផ្លូវការលើកដំបូងនៅទីក្រុងឡុងដ៍ ប្រទេសអង់គ្លេសនៅថ្ងៃទី ១០ ខែមករា ឆ្នាំ១៨៦៣ ដោយខ្សែរថភ្លើងនេះអាចដឹកជញ្ជូនអ្នកដំណើរបាន ៣០,០០០នាក់។ ខ្សែរថភ្លើងក្រោមដីដំបូងរបស់ទីក្រុងឡុងដ៍នេះ បានបង្ហាញពីប្រសិទ្ធភាពនៃការដឹកជញ្ជូនដ៏ធំធេង ជួយសម្រួលដល់ការកកស្ទះចរាចរណ៍នៅតាមដងផ្លូវ[7]។ ខ្សែរថភ្លើងក្រោមដីដំបូងដែលល្បីល្បាញទូទាំងពិភពលោកនេះចាប់ផ្ដើមមានការត្អូញត្អែរជាច្រើនដោយសារតែផ្សែងនៅក្នុងរូងក្រោមដីបន្តសាយភាយ។ ឆ្នាំ១៨៩០ អង់គ្លេសបង្កើតប្រវត្តិសាស្ត្រថ្មីមួយទៀតដោយចាប់ផ្ដើមប្រើប្រាស់រថភ្លើងប្រើម៉ាស៊ីនអគ្គីសនីវិញម្ដង។ ដោយនេះជាការចាប់ផ្ដើមយុគសម័យថ្មីនៃការដឹកជញ្ជូនដែលមានល្បឿនលឿននៅក្នុងទីក្រុង ហើយខ្សែរថភ្លើងក្រោមដីក៏លេចរូបរាងឡើងនៅបណ្ដាប្រទេសផ្សេងៗជាបន្តបន្ទាប់[8]។ នៅក្នុងឆ្នាំ ១៩១៣ ក្បាលរថភ្លើងដើរដោយថាមពលប្រេងបានលេចរូបរាងឡើងនៅប្រទេសស៊ុយអែត ហើយសហរដ្ឋអាមេរិកចាប់ផ្ដើមប្រើក្បាលរថភ្លើងដើរដោយថាមពលប្រេងនេះក្នុងឆ្នាំ ១៩៣៩[9]។ ក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៦០ ប្រទេសជាច្រើនដែលប្រើប្រាស់ក្បាលរថភ្លើងដែលដើរដោយថាមពលប្រេងនោះបានផ្លាស់ប្ដូរមកប្រើក្បាលរថភ្លើងដែលដើរដោយថាមពលអគ្គីសនីជំនួសវិញ ប៉ុន្តែអ្វីដែលគួរឲ្យចាប់អារម្មណ៍ជាងនេះទៀតនោះគឺ ប្រទេសជប៉ុនចាប់ផ្ដើមមានផ្លូវដែកដែលមានល្បឿនលឿនប្រើសម្រាប់ការដឹកជញ្ជូនផ្លូវឆ្ងាយដោយអាចបង្កើនល្បឿនរហូតដល់ ៣៥០គីឡូម៉ែត្រក្នុងមួយម៉ោង[10]។ ផ្លូវដែកដែលមានល្បឿនលឿនលើកដំបូងមានខ្សែរត់នៅរវាងទីក្រុងតូក្យូ និងទីក្រុងអូសាកានៅក្នុងប្រទេសជប៉ុនដែលបានដំណើរការនៅឆ្នាំ ១៩៦៤[11]។

---

[6] Anand Kumar Choudhary និង Dr. Srinivas Rao, "History of Rail Transportation and Importance Indian Railway Transportation", https://www.ijedr.org/papers/IJEDR1803014.pdf

[7] Christopher Klein, "10 Trains that changed the world", ថ្ងៃទី ០១ កញ្ញា ឆ្នាំ២០១៨, https://www.history.com/news/10-trains-that-changed-the-world

[8] Train History, "History of Rail Transport", http://www.trainhistory.net/railway-history/railroad-history/

[9] Train History, 'Railway Timeline-Important Moments in Railway History", http://www.trainhistory.net/railway-history/railroad-timeline/

[10] Anand Kumar Choudhary និង Dr. Srinivas Rao, "History of Rail Transportation and Importance Indian Railway Transportation", https://www.ijedr.org/papers/IJEDR1803014.pdf

[11] Mary Bellis, "The History of the Railroad", ថ្ងៃទី ២៤ កញ្ញា ឆ្នាំ២០១៨, https://www.thoughtco.com/history-of-railroad-4059935

## ១.៣ ប្រភេទនៃផ្លូវដែក

ផ្លូវដែក គឺជាវិធីសាស្ត្រដឹកជញ្ជូនមួយប្រកបដោយសុវត្ថិភាពខ្ពស់ និងចំណាយប្រាក់តិច សម្រាប់អ្នកដំណើរ និងការដឹកជញ្ជូនទំនិញ។ វិស័យដឹកជញ្ជូនតាមផ្លូវដែកទទួលបានអ្នកដំណើរសរុបលើពិភពលោកចំនួន ៨% និង ៧% លើការដឹកជញ្ជូនទំនិញតាមរយៈផ្លូវដែក។ បច្ចុប្បន្ននេះ សកម្មភាពដឹកជញ្ជូនតាមផ្លូវដែករបស់អ្នកដំណើរចំនួន ៣ភាគ៤ បានកើតឡើងលើរថភ្លើងអគ្គិសនី។ តំបន់ដែលប្រើរថភ្លើងអគ្គិសនីច្រើនបំផុតគឺ មាននៅអឺរ៉ុប, ជប៉ុន, និងរុស្ស៊ី ខណៈដែលទ្វីបអាមេរិក នៅតែពឹងផ្អែកលើរថភ្លើងប្រើម៉ាស៊ូត[12]

ប្រភេទនៃផ្លូវដែកសម្រាប់ដឹកជញ្ជូនសព្វថ្ងៃចែកជា[13]៖

- ផ្លូវរថភ្លើងធម្មតា៖ ផ្លូវដែកធ្វើដំណើររយៈចម្ងាយឆ្ងាយ និងមានល្បឿនអតិបរមាក្រោម ២៥០ គីឡូម៉ែត្រក្នុងមួយម៉ោង និងភាគច្រើនមាននៅជាយក្រុង។ អ្នកដំណើរប្រហែល ៩០% ទូទាំងសាកលលោកជ្រើសរើសផ្លូវរថភ្លើងនេះច្រើនជាងគេ គឺនៅប្រទេសឥណ្ឌា ប្រមាណ ៣៩%, ប្រទេសចិន ២៧%, ប្រទេសជប៉ុន ១១% និងសហភាពអឺរ៉ុប ៩%។
- ផ្លូវរថភ្លើងល្បឿនលឿន៖ ជាផ្លូវដែកធ្វើដំណើរចម្ងាយឆ្ងាយរវាងស្ថានីយមួយទៅស្ថានីយមួយក្នុងល្បឿនអតិបរមាលើសពី ២៥០ គីឡូម៉ែត្រក្នុងមួយម៉ោង។
- ផ្លូវរថភ្លើងក្រោមដី៖ ជាផ្លូវដែកដែលមានខ្សែរត់នៅក្រោមដី។
- ផ្លូវដែកធុនស្រាល៖ ជាផ្លូវដែកដែលមានល្បឿនអតិបរមាទាប និងមានខ្សែរត់នៅលើផ្លូវថ្នល់។

## ១.៤ អត្ថប្រយោជន៍នៃការដឹកជញ្ជូនតាមរយៈផ្លូវដែក

នៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍ សេវាកម្មដឹកជញ្ជូនតាមផ្លូវដែកមានសារៈសំខាន់ចំពោះការធ្វើពាណិជ្ជកម្ម និងការចែកចាយវត្ថុធាតុដើម ដែលភាគច្រើនមានដូចជា ធ្យូង,រ៉ែ, ប្រេង, ផលិតផលគ្រាប់ធញ្ញជាតិ, សារធាតុគីមី, ដែកថែប, ស៊ីម៉ង់, ឈើ, ខ្សាច់, និងក្រួស។ នៅលើចម្ងាយផ្លូវឆ្ងាយដែលរថភ្លើងអាចមានលទ្ធភាពទ្រទ្រង់នូវទំនិញដែលធំៗ និងមានទម្ងន់ធ្ងន់ប្រកប ដោយប្រសិទ្ធភាព និងសុវត្ថិភាពសម្រាប់ការដឹកជញ្ជូនទូទៅ។ ជាពិសេសនៅក្នុងសកម្មភាពនៃដឹកជញ្ជូនកុងតឺន័រពីកំពង់ផែទៅឃ្លាំងនីមួយៗ។ ការដឹកជញ្ជូនតាមរយៈផ្លូវដែកបានផ្តល់អត្ថប្រយោជន៍ជាច្រើន

[12] Dr. Faith Birol, "The Future of Railway Opportunities for energy and the environment", https://www.iea.org/futureofrail/

[13] Ibid

ដោយផ្តោតលើការកាត់បន្ថយការធ្វើដំណើរទូទៅ (ទាំងថ្លៃចំណាយ និងរយៈពេល)។ ការកាត់បន្ថយចំណាយបែបនេះធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃវិស័យជំនួញ ដោយកាត់បន្ថយថ្លៃដើមទំនិញគាំទ្រដល់ការពង្រីកសេដ្ឋកិច្ច និងជួយសម្រួលដល់ការទទួលបានឱកាសការងារ និងកម្សាន្ត។ ចរាចរតាមផ្លូវរថភ្លើងបានផ្តល់អត្ថប្រយោជន៍ដូចជាកាត់បន្ថយចរាចររថយន្តធុនធំលើផ្លូវថ្នល់ ដូច្នេះនាំឲ្យកាត់បន្ថយការចំណាយលើការថែទាំ និងការពង្រីកផ្លូវថ្នល់នាពេលអនាគតក៏ដូចជាកាត់បន្ថយគ្រោះថ្នាក់ដែលអាចកើតមានជាយថាហេតុ។ ម្យ៉ាងវិញទៀត កាត់បន្ថយការដឹកប្រេង និងទំនិញគ្រោះថ្នាក់ផ្សេងៗតាមដងផ្លូវ ដូច្នេះនាំឲ្យកាត់បន្ថយហានិភ័យចរាចរផ្លូវគោក។ លើសពីនេះផ្លូវរថភ្លើងអាចផ្តល់នូវការដឹកជញ្ជូនដែលមានតម្លៃថោកសម្រាប់ទំនិញដុលដូចជាស៊ីម៉ង់ និងប្រេង ដូច្នេះនាំឲ្យកាត់បន្ថយចំណាយការនាំចូល និងចែកចាយផលិតផលជាមូលដ្ឋាន និងបង្កើនគំនាបប្រកួតប្រជែងលើប្រព័ន្ធដឹកជញ្ជូនបច្ចុប្បន្នជាចម្បង គឺការដឹកជញ្ជូនផ្លូវគោក និងកំពង់ផែក្រុងព្រះសីហនុតាមរយៈការបង្កើតនូវច្រកផ្លូវ និងមធ្យោបាយដឹកជញ្ជូនផ្សេងៗ។ វានឹងជួយបន្ថយនូវការអនុវត្តការកំណត់តម្លៃផ្តាច់មុខ។ បន្ថែមពីនេះវានឹងជួយជម្រុញសមាហរណកម្ម និងពាណិជ្ជកម្មក្នុងតំបន់ក៏ដូចជាវិស័យទេសចរណ៍ ទន្ទឹមនឹងការបង្កើតការងារបន្ថែមសម្រាប់ប្រជាជន[14]។

លោក Ajai ក្នុងឆ្នាំ២០០៥ បានបង្ហាញយ៉ាងច្បាស់ថាផ្លូវដែកនេះមានសក្តានុពលនៃការផ្លាស់ប្តូរកំណើនសេដ្ឋកិច្ចដោយសារតែ[15]៖

- វាអាចដើរតួជាកាតាលីករសម្រាប់ការអភិវឌ្ឍប្រទេសជាតិ ព្រោះវាមានលទ្ធភាពបង្កើតការងារដល់អ្នកដែលគ្មានការងារធ្វើជាច្រើននាក់ ដូច្នេះវាអាចជួយកាត់បន្ថយអត្រាគ្មានការងារធ្វើនៅក្នុងប្រទេស
- កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ បើធៀបនិងការប្រើមធ្យោបាយដឹកជញ្ជូនផ្សេងទៀត
- វាមានសមត្ថភាពដល់សេវាដឹកជញ្ជូនដែលនាំមកនូវបរិស្ថានល្អជាងមធ្យោបាយដឹកជញ្ជូនដទៃទៀត។

ទាំងនេះបានកាត់បន្ថយចំណាយទូទៅនៃការដឹកជញ្ជូន និងបង្កើនឱកាសសម្រាប់ការធ្វើដំណើរ និងពាណិជ្ជកម្មដែលការដឹកជញ្ជូនតាមផ្លូវដែកអាចមានតួនាទីសំខាន់ចំពោះសេដ្ឋកិច្ច។

---

[14] ឯឧបណ្ឌិត ហាង់ ជួនណារ៉ុង, "សេដ្ឋកិច្ចកម្ពុជា" ទំព័រ ៣២៨

[15] Joyce Etim, Rail Transport: Definition, Types, Advantages and Disadvantages of Rail Transport, ថ្ងៃទី ១៦ មករា ឆ្នាំ២០១៨, http://www.jotscroll.com/forums/3/posts/195/rail-transport-definition-types-advantages-and-disadvantages.html

## ១.៥ ការរីកចម្រើននៃផ្លូវដែកនៅបរទេស

### ១.៥.១ ករណីសិក្សាប្រទេសឥណ្ឌូនេស៊ី

នៅក្នុងប្រទេសឥណ្ឌូនេស៊ីរថភ្លើងជាមធ្យោបាយដឹកជញ្ជូនមួយដែលមានគុណសម្បត្តិជាច្រើនបើប្រៀបធៀបនឹងមធ្យោបាយដឹកជញ្ជូនផ្សេងទៀត។ ការដឹកជញ្ជូនតាមរយៈរថភ្លើងផ្តល់សុវត្ថិភាពដល់យានយន្តតាមដងផ្លូវដោយកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកដោយសារតែរថភ្លើងគឺ រត់តែនៅលើផ្លូវដែករបស់ខ្លួនប៉ុណ្ណោះ។ ដោយហេតុប្រទេសឥណ្ឌូនេស៊ីមានបញ្ហាដឹកជញ្ជូនដែលកំពុងជួបប្រទះដូចជា៖ ផ្លូវគោកខូចខាតច្រើន, ការកកស្ទះចរាចរណ៍ដោយសារតែការកើនឡើងនៃយានយន្ត, និងការកើនឡើងនៃតម្លៃប្រេងឥន្ធនៈដែលនាំឲ្យមានការចំណាយលើការដឹកជញ្ជូនកើនឡើង។ ប្រទេសឥណ្ឌូនេស៊ីក៏ប្តូររបៀបនៃការដឹកជញ្ជូនតាមផ្លូវគោកមកប្រើសេវាដឹកជញ្ជូនតាមផ្លូវដែកវិញ ដែលធ្វើឲ្យការដឹកជញ្ជូនតាមរថភ្លើងក្លាយជាសេវាដឹកជញ្ជូនពេញនិយមនៅឥណ្ឌូនេស៊ី។ គេអាចសង្កេតមើលឃើញពីការរីកចម្រើននៃសេវាដឹកជញ្ជូនតាមរថភ្លើងដោយអ្នកដំណើរជាច្រើនចាប់ផ្តើមធ្វើដំណើរគ្រប់ទិសទីតាមរថភ្លើង ហើយក៏មានមនុស្សដែលទិញសំបុត្ររថភ្លើងដើម្បីធ្វើដំណើរក្នុងអំឡុងថ្ងៃឈប់សម្រាកផ្សេងៗ[16]។

រដ្ឋបាលផ្លូវដែករបស់ឥណ្ឌូនេស៊ីត្រូវបានបែងចែកជា ២គឺ៖ ផ្នែកផ្លូវដែកគឺស្ថិតក្រោមជាគ្រប់គ្រងរបស់រដ្ឋាភិបាល ដែលមានអគ្គនាយកដ្ឋានផ្លូវដែកនៃក្រសួងដឹកជញ្ជូនរបស់ឥណ្ឌូនេស៊ីដែលបានបង្កើតឡើងក្នុងឆ្នាំ២០០៧។ អគ្គនាយកដ្ឋាននេះមានមុខងារដូចជា[17]៖

១. រៀបចំគោលនយោបាយស្តីពីការអភិវឌ្ឍផ្លូវដែក និងការគ្រប់គ្រងផ្លូវដែក។
២. ការរៀបចំការអនុវត្តគោលនយោបាយគ្រប់គ្រងសុវត្ថិភាពចរាចរណ៍ផ្លូវដែក និងហេដ្ឋារចនាសម្ព័ន្ធផ្លូវដែក។
៣. រៀបចំបទដ្ឋាននីតិវិធីសម្រាប់ការគ្រប់គ្រងផ្លូវដែក។
៤. ការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់បម្រើឲ្យវិស័យផ្លូវដែក។
៥. រៀបចំការអនុវត្តរដ្ឋបាលក្នុងអគ្គនាយកដ្ឋានផ្លូវដែក។

ចំណែកឯការធ្វើប្រតិបត្តិការគឺស្ថិតក្រោមការគ្រប់គ្រងរបស់ក្រុមហ៊ុន PT Kereta Api Indonesia (PT KAI) ដែលមានសេវាកម្មដូចជា[18]៖

[16] Organisation for Economic Co-operation and Development, "Recent developments in rail transportation services", ថ្ងៃទី ១៣ ធ្នូ ២០១៣, ទំព័រ ១១៣ ដល់ ១២៣

[17] Ibid

[18] Ibid

១. សេវាកម្មដឹកជញ្ជូនអ្នកដំណើរ និងទំនិញ

២. សេវាកម្មជួលឃ្លាំងស្តុកទំនិញក្នុងស្ថានីយ និងសេវាកម្មជួលផុលកុងតឺន័រ។

ប្រវែងផ្លូវដែកបច្ចុប្បន្ននៅប្រទេសឥណ្ឌូនេស៊ីគឺ ៦,៥៤៦ គីឡូម៉ែត្រ។ ក្នុងនោះមាន ១០០ គីឡូម៉ែត្រដែលប្រើរថភ្លើងដើរដោយថាមពលអគ្គីសនីដែលមាននៅក្នុងទីក្រុងចាកាតា (Jakarta), បូហ្គ័រ (Bogor), ដេប៉ក (Depok), ធ័រម៉ាង (Tangerang) និងបេកស៊ី (Bekasi)។ ក្នុងឆ្នាំ ២០១២ រដ្ឋាភិបាលឥណ្ឌូនេស៊ីចាប់ផ្តើមសាងសង់បន្ថែមនៅតាមបណ្តាកោះដែលមិនទាន់មានផ្លូវដែក[19]។

បើទោះបីជាមានការវិនិយោគពីក្រុមហ៊ុនឯកជនក៏ដោយ រដ្ឋាភិបាលបានចែងអំពីគោលការណ៍ណែនាំស្តីពីការដឹកជញ្ជូនអ្នកដំណើរ និងថ្លៃដឹកជញ្ជូនទំនិញដែលត្រូវប្រើប្រាស់សម្រាប់ការគណនាថ្លៃឈ្នួលដែលកំណត់ដោយអ្នកគ្រប់គ្រងផ្លូវដែក។ បញ្ហាដែលវិស័យដឹកជញ្ជូនតាមរថភ្លើងបានជួបគឺអំឡុងឆ្នាំ ២០០២ នៅពេលដែលមានការជ្រៀតជ្រែកពីវិស័យអាកាសចរណ៍នាំឲ្យមានការប៉ះពាល់យ៉ាងខ្លាំងដល់សេវាដឹកអ្នកដំណើរដោយសារអាជ្ញាធរគ្រប់គ្រងផ្នែកអាកាសចរស៊ីវិលរបស់ឥណ្ឌូនេស៊ីមិនអាចកំណត់ថ្លៃនៃការដឹកជញ្ជូនរបស់ក្រុមហ៊ុនអាកាសចរណ៍បានដែលធ្វើឲ្យមានការទម្លាក់ថ្លៃដើម្បីប្រកួតប្រជែងជាមួយក្រុមហ៊ុនអាកាសចរណ៍ផ្សេងទៀត ហើយបានទាក់ទាញអ្នកដំណើរធ្លាប់ជិះរថភ្លើងផ្លាស់ប្តូរគំនិតទៅជ្រើសរើសយកការធ្វើដំណើរតាមផ្លូវអាកាសវិញដែលចំណាយថវិកាប្រហាក់ប្រហែលគ្នាជាមួយសេវាផ្លូវដែក និងចំណេញពេលវេលាជាងការជិះរថភ្លើង។ ផ្លូវដែកដែលជួបប្រទះបញ្ហាប្រឈមដ៏លំបាកបំផុតនោះ គឺខ្សែរត់ពីចាកាតា (Jakarta) ទៅស៊ូរ៉ាបាយ៉ា (Surabaya) ពីព្រោះវាជាផ្លូវដែលមានប្រជាជនធ្វើដំណើរទៅមកច្រើន ដោយមុនពេលដែលមានបញ្ហានេះកើតឡើងអ្នកដំណើរប្រមាណ ៨១% ជ្រើសរើសយកការជិះរថភ្លើង ប៉ុន្តែចំនួននេះធ្លាក់ចុះមកត្រឹម ៤០% បន្ទាប់ពីមានបញ្ហាប្រកួតប្រជែងជាមួយក្រុមហ៊ុនអាកាសចរណ៍មក[20]។

រដ្ឋាភិបាលបានបើកច្រកផ្លូវគោកមួយឈ្មោះ Cipularang ដែលតភ្ជាប់ពីចាកាតា (Jakata) ទៅ បង់ដុង (Bandung)។ ការបើកច្រកផ្លូវគោកថ្មីនេះធ្វើឲ្យការធ្វើដំណើរតាមរថភ្លើងមានចំនួនធ្លាក់ចុះយ៉ាងខ្លាំងដោយសារតែការធ្វើដំណើរតាមរថភ្លើងត្រូវប្រើរយៈពេល ៤ម៉ោង ប៉ុន្តែសម្រាប់ច្រកផ្លូវគោកថ្មីនេះសម្រាប់រថយន្តប្រើពេលតែ ២ម៉ោងប៉ុណ្ណោះ[21]។

---

[19] Organisation for Economic Co-operation and Development, “Recent developments in rail transportation services”, ថ្ងៃទី ១៣ ធ្នូ ២០១៣, ទំព័រ ១១៣ ដល់ ១២៣

[20] Ibid

[21] Ibid

ដើម្បីជៀសវាងពីបញ្ហានៃការធ្លាក់ចុះនៃអ្នកដំណើរនេះ ក្រុមហ៊ុន PT KAI បានដាក់ចេញនូវដំណោះស្រាយមួយចំនួនដើម្បីបញ្ចៀសពីបញ្ហាទាំងនេះដូចជា[22]៖

- ការប្តូរតម្លៃសំបុត្រតាមថ្ងៃ៖ កាលពីមុនតម្លៃសំបុត្រត្រូវបានលក់ក្នុងតម្លៃស្មើគ្នាមិនថាថ្ងៃធម្មតា ឬថ្ងៃចុងសប្តាហ៍។ ក្រោយពីជួបបញ្ហាធ្លាក់ចុះនៃអ្នកដំណើរ គេបានប្តូរតម្លៃសំបុត្រថ្ងៃធម្មតា (ច័ន្ទ-ព្រហ) ទាបជាងតម្លៃសំបុត្រថ្ងៃចុងសប្តាហ៍ (សុក្រ-អាទិត្យ)។
- ការបង់ប្រាក់តាមចម្ងាយដែលអ្នកដំណើរជិះ៖ កាលពីមុនបើអ្នកដំណើរជិះរថភ្លើងរយៈចម្ងាយជិតក៏ដោយក៏ត្រូវបង់ប្រាក់ពេញថ្លៃស្មើអ្នកជិះឆ្ងាយដែរ ប៉ុន្តែគេបានប្តូរការទូទាត់វិញដោយគិតតាមចម្ងាយដែលអ្នកដំណើរជិះពីស្ថានីយមួយទៅស្ថានីយមួយទៀត។
- ការលក់សំបុត្រ និងបង្ហាញព័ត៌មានពេលវេលាចេញដំណើរតាមប្រព័ន្ធអ៊ីនធឺណេត៖ ក្រុមហ៊ុន PT KAI បានពង្រឹងសេវាលក់សំបុត្ររបស់ខ្លួនតាមអ៊ីនធឺណេត ដោយផ្តល់ភាពកាន់តែងាយស្រួលដល់អ្នកដំណើរជាមួយការផ្តល់ព័ត៌មានពេលវេលាការចាកចេញរបស់រថភ្លើងជាដើម។
- ការដឹកជញ្ជូនទំនិញដល់ដៃអតិថិជន៖ ក្រុមហ៊ុន PT KAI បានផ្តល់សេវាដឹកជញ្ជូនទំនិញបន្តដល់ទីកន្លែងរបស់អតិថិជន។

### ១.៥.២ ករណីសិក្សាប្រទេសថៃ

កាលពីអតីតកាលផ្លូវដែកត្រូវបានប្រើប្រាស់ជាញឹកញាប់បំផុតសម្រាប់ការដឹកជញ្ជូន។ ការដឹកជញ្ជូនតាមរយៈរថភ្លើងភាគច្រើនជាផលិតផលប្រេងដែលជាចំណែកតិចតួចនៃការដឹកជញ្ជូនទំនិញសរុបរបស់ជាតិ។ ប្រាក់ចំណូលបានពីផ្លូវដែកចាប់ផ្តើមធ្លាក់ចុះជាការលំបាកបំផុតសម្រាប់វិស័យផ្លូវដែកថៃក្នុងការបង្កើនប្រាក់ចំណូលពីសេវាដឹកជញ្ជូន។ ទោះជាយ៉ាងសេវាដឹកជញ្ជូនចាប់ផ្តើមផ្លាស់ប្តូរក្នុងរយៈពេលប៉ុន្មានទសវត្សរ៍កន្លងមកនេះ[23]។ នៅរយៈពេលដប់ឆ្នាំចុងក្រោយនេះតម្រូវការនៃការដឹកជញ្ជូនតាមរថភ្លើងចាប់ផ្តើមកើនឡើងដោយមានការដឹកជញ្ជូនកុងតឺន័រដែល

---

[22] Organisation for Economic Co-operation and Development, "Recent developments in rail transportation services", ថ្ងៃទី ១៣ ធ្នូ ២០១៣, ទំព័រ ១១៣ ដល់ ១២៣

[23] Pongtana Vanichkobchinda, "The development of Thailand railway Freight Transportation: A key Element to become the Great Mekong Subregion (GMS) Freight Distribution Center"

តភ្ជាប់ពីកំពង់ផែ Leam Chabang នៅច្រាំងសមុទ្រខាងកើត ទៅឃ្លាំងស្តុកទំនិញ ឡាតក្រាបាង (Lad Krabang) បានបន្តកើនឡើង[24]។

បញ្ហាដែលរារាំងការរីកចម្រើននៃការដឹកជញ្ជូនតាមផ្លូវដែកនៅប្រទេសថៃមានដូចជា[25]៖

- ចំណាប់អារម្មណ៍របស់អ្នកដំណើរទៅលើផ្លូវដែក គឺនៅទាបបើធៀបនិងការធ្វើដំណើរតាមផ្លូវគោក
- ការខ្វះខាតបទពិសោធន៍ផ្នែកបច្ចេកទេស និងបញ្ហាឧបករណ៍បរិក្ខាសម្រាប់បម្រើការក្នុងដំណើរការនៃការធ្វើដំណើររបស់រថភ្លើង
- បញ្ហាក្បាលម៉ាស៊ីនចាស់រួមទាំងទូរថភ្លើងចាស់ៗ ខ្វះស្តង់ដាសម្រាប់ការដឹកជញ្ជូនអ្នកដំណើរ និងទំនិញ។ ការខូចខាតផ្លូវដែក និងពេលកំណត់ដែលត្រូវផ្លាស់ប្តូរជាច្រើនមិនទាន់មានការជួសជុលដែលធ្វើឲ្យរំខានដល់ប្រតិបត្តិការផ្លូវដែក។

តារាងទី១ ៖ ចំនួន និងអាយុកាលរបស់ក្បាលម៉ាស៊ីន និងទូរថភ្លើង

| **ចំនួនឆ្នាំ** | **ក្បាលម៉ាស៊ីនរថភ្លើង** | **ទូរថភ្លើង** |
|---|---|---|
| ១ ដល់ ១៥ | ៣១% | ៣១% |
| ១៦ ដល់ ៣០ | ៣៦% | ៣៦% |
| លើសពី ៣០ | ៣៣% | ៣៣% |

ប្រភពពី៖ The development of Thailand railway Freight Transportation: A Key Element to become the Great Mekong Subregion (GMS) Freight Distribution Center

ដូចដែលបានបង្ហាញក្នុងតារាងខាងលើ ក្បាលរថភ្លើង និងទូររថភ្លើងរបស់ថៃដែលមានអាយុកាល ១៦ ទៅ ៣០ឆ្នាំមានចំនួន ៣៦ភាគរយ ។ ក្បាល និងទូររថភ្លើងមានអាយុកាល លើសពី៣០ឆ្នាំ មាន៣៣ភាគរយ និង ៣១ភាគរយដែលជាក្បាលរថភ្លើង ដែលមានអាយុកាល១ឆ្នាំទៅ១៥ឆ្នាំ។

ទន្ទឹមនឹងបញ្ហានេះ ប្រទេសថៃមានដំណោះស្រាយដើម្បីបង្កើនសេវាដឹកជញ្ជូនតាមផ្លូវដែកឲ្យកាន់តែមានប្រសិទ្ធភាពថែមមួយកម្រិតទៀត ដោយដំណោះស្រាយនោះមានដូចជា[26]៖

- ការកែលម្អស្ថានីយ

[24] Pongtana Vanichkobchinda, "The development of Thailand railway Freight Transportation: A key Element to become the Great Mekong Subregion (GMS) Freight Distribution Center"

[25] Ibid

[26] Ibid

- ចាប់ផ្តើមធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ
- ការពង្រីកស្ថានីយដឹកជញ្ជូនបន្ថែម
- ពង្រីកសេវាដឹកជញ្ជូនកុងតឺន័រ។

### ១.៥.៣ ករណីសិក្សាប្រទេសម៉ាឡេស៊ី

សេវាកម្មដឹកជញ្ជូនតាមរថភ្លើងក្លាយជាការដឹកជញ្ជូនមួយបែបដែលអាចបញ្ចៀសការកកស្ទះចរាចរណ៍ និងមានសុវត្ថិភាពនៅប្រទេសម៉ាឡេស៊ី។ នៅពេលកន្លងមកប្រព័ន្ធនៃការដឹកជញ្ជូនតាមផ្លូវដែកនៅម៉ាឡេស៊ីនៅមានកម្រិតនៅឡើយ។ ដោយមើលឃើញបញ្ហាដែលកើតឡើងជាបន្តបន្ទាប់របស់ប្រទេសម៉ាឡេស៊ីបានបែងចែកការដឹកជញ្ជូនតាមផ្លូវដែកជា ២ប្រភេទគឺ ការដឹកជញ្ជូននៅក្នុងទីក្រុង និងទីជនបទ។ ប្រព័ន្ធដឹកជញ្ជូនផ្លូវដែកនៅក្នុងទីក្រុងត្រូវបានបង្កើតឡើងដំបូងដើម្បីកាត់បន្ថយការកកស្ទះចរាចរណ៍ ដោយកសាងផ្លូវតភ្ជាប់ពីតំបន់មួយទៅតំបន់ដើម្បីផ្តល់ភាពងាយស្រួលដល់ប្រជាជនមានជម្រើសសម្រាប់ការធ្វើដំណើរ។ ប្រជាជនដែលធ្វើការក្នុងទីក្រុងកូឡាឡាំពួរមួយចំនួនរស់នៅជាយក្រុង ដូច្នេះការបង្កើតសេវាដឹកជញ្ជូនតាមផ្លូវដែកបានផ្តល់ភាពងាយស្រួលដល់ពួកគេសម្រាប់ការធ្វើដំណើរមកធ្វើការ និងត្រឡប់ទៅផ្ទះវិញ។ ស្របពេលដែលមានការធ្វើដំណើរចេញចូលទីក្រុងច្រើន។ រដ្ឋាភិបាលម៉ាឡេស៊ីក៏បានបង្កើតរថភ្លើងក្រោមដីថែមទៀតដើម្បីបញ្ចៀសភាពតានតឹង និងមមាញឹកនៃការធ្វើដំណើរ។ ក្រៅពីការបង្កើនសមត្ថភាពដឹកជញ្ជូនក្នុងទីក្រុងហើយ រដ្ឋាភិបាលចាប់ផ្តើមពង្រីកខ្សែរត់កាត់តាមតំបន់ផ្សេងៗដោយផ្តល់នូវការដឹកជញ្ជូនដែលអាចទុកចិត្តបាន, មានល្បឿនលឿន, និងមានតម្លៃសមរម្យ។ ប្រតិបត្តិការនៃការផ្តល់សេវាដឹកជញ្ជូននេះកាន់តែប្រសើរដោយអាចបំពេញតម្រូវការ និងការពេញចិត្តរបស់អ្នកដំណើរដែលធ្វើឲ្យសេវាដឹកជញ្ជូនតាមផ្លូវដែកទទួលការចាប់អារម្មណ៍កាន់តែខ្លាំងឡើងៗ និងទាក់ទាញអ្នកដំណើរដែលធ្លាប់តែជ្រើសរើសការធ្វើដំណើរតាមរថយន្តផ្ទាល់ខ្លួន ឬរថយន្តក្រុងឲ្យងាកមករើសយកការដឹកជញ្ជូនតាមរថភ្លើងវិញ[27]។

បន្ទាប់ពីមានការពង្រីកសេវាកម្មដឹកជញ្ជូនតាមផ្លូវដែក ក្រុមហ៊ុនវិនិយោគលើសេវានេះក៏កាន់តែមានចំនួនច្រើនឡើង រដ្ឋាភិបាលម៉ាឡេស៊ីបានដាក់ចេញនូវវិធានការសុវត្ថិភាពសម្រាប់

[27] Noor Hafiza Binti Nordin, Mohd Idrus Mohd Masirin, Imran bin Ghazali និង Mohd Isom bin Azis, "Apraisal on Rail Transit Development: A Review on Train Service And Safety"

ប្រតិបត្តិការនៃការដឹកជញ្ជូនដោយតម្រូវឲ្យវិនិយោគិនដែលជាក្រុមហ៊ុនឯកជនគោរពតាមនូវបទបញ្ញាដូចខាងក្រោម[28]៖

- វិញ្ញាបនបត្រសុវត្ថិភាព៖ វិញ្ញាបនបត្រនេះតម្រូវឲ្យក្រុមហ៊ុនឯកជនទាំងអស់ដែលទទួលបានអាជ្ញាប័ណ្ណវិនិយោគលើសេវាដឹកជញ្ជូនតាមផ្លូវដែកត្រូវតែគោរពតាមតម្រូវការរបស់ជាតិស្របតាមច្បាប់ដែលបានចែងទាក់ទងនឹងស្តង់ដាសុវត្ថិភាព ,ពេលវេលា និងល្បឿននៃការបើកបរ
- ការថែទាំក្បាល និងទូរថភ្លើង៖ ក្បាលរថភ្លើង និងទូរថភ្លើងស្ថិតក្រោមការថែទាំរបស់អង្គភាពថែទាំដែលអាចធានានូវដំណើរការនៃក្បាល និងទូរថភ្លើងត្រឹមត្រូវតាមស្តង់ដា
- ការបង្កើតអាជ្ញាធរសុវត្ថិភាពជាតិ៖ ស្ថាប័ននេះបង្កើតឡើងសម្រាប់គ្រប់គ្រងលើកិច្ចការសុវត្ថិភាពនៃប្រតិបត្តិការ។ អាជ្ញាធរសុវត្ថិភាពជាតិមានសិទ្ធិធ្វើការត្រួតពិនិត្យលើប្រព័ន្ធប្រតិបត្តិការរបស់ក្រុមហ៊ុនឯកជន និងអាចពិនិត្យមើលឯកសារដែលពាក់ព័ន្ធនឹងប្រតិបត្តិការទាំងអស់
- ការិយាល័យសុវត្ថិភាពផ្លូវដែក៖ ការិយាល័យនេះបង្កើតឡើងសម្រាប់ផ្តោតលើការលើកកម្ពស់សុវត្ថិភាពផ្លូវដែកដែលមានបុគ្គលិកជំនាញប្រមាណ ៥០០នាក់សម្រាប់គ្រប់គ្រងបច្ចេកទេសផ្លូវដែក និងប្រព័ន្ធភ្លើងសញ្ញានៅតាមផ្លូវដែកដើម្បីការពារគ្រោះថ្នាក់អំឡុងពេលរថភ្លើងធ្វើការឆ្លងកាត់។

[28] Noor Hafiza Binti Nordin, Mohd Idrus Mohd Masirin, Imran bin Ghazali និង Mohd Isom bin Azis, "Apraisal on Rail Transit Development: A Review on Train Service And Safety"

# ជំពូកទី២
# ស្ថានភាពទូទៅនៃផ្លូវដែកកម្ពុជា

## ២.១ ប្រវត្តិនៃការកកើតផ្លូវដែកនៅកម្ពុជា

### ២.១.១ ប្រវត្តិផ្លូវដែកកម្ពុជា

ផ្លូវដែកកម្ពុជា បានចាប់ផ្តើមសាងសង់ដំបូងក្នុងទសវត្សរ៍ឆ្នាំ ១៩៣០ ដល់ឆ្នាំ ១៩៤០។ ផ្លូវដែកកម្ពុជាមានចំនួន ២ខ្សែ គឺខ្សែខាងជើង និងខ្សែខាងត្បូង ដែលមានប្រវែងសរុប ៦៥០ គីឡូម៉ែត្រ[29]។ ផ្លូវដែកភាគខាងជើង មានប្រវែង ៣៨៦គីឡូម៉ែត្រ ពីភ្នំពេញ ទៅដល់ប៉ោយប៉ែត (ព្រំដែនកម្ពុជា-ថៃ) ត្រូវបានកសាងឡើងចាប់ពីឆ្នាំ ១៩២៩ ដល់ឆ្នាំ ១៩៤២ ក្នុងសម័យអាណានិគមបារាំង ហើយផ្លូវដែកភាគខាងត្បូងត្រូវបានកសាងឡើងនៅចន្លោះឆ្នាំ ១៩៦០ ដល់ឆ្នាំ ១៩៦៩ ក្នុងសម័យសង្គមរាស្ត្រនិយមក្រោមព្រះរាជកិច្ចដឹកនាំរបស់ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ក្រោមជំនួយរបស់ប្រទេសបារាំង អាល្លឺម៉ង់ខាងលិច និងចិន ដែលមានប្រវែងសរុប ២៦៤គីឡូម៉ែត្រ[30]។ ផ្លូវដែកទាំងពីរខ្សែនេះបានទទួលរងការខូចខាតយ៉ាងធ្ងន់ធ្ងរ ហើយផ្នែកខ្លះត្រូវបានបំផ្លាញទាំងស្រុងដោយរបបកម្ពុជាប្រជាធិបតេយ្យ[31]។

ខ្សែផ្លូវខាងជើងមានប្រវែងសរុប ៣៣៨ គីឡូម៉ែត (ភ្នំពេញ-ស៊ីសុផុន)។ ៤៨គីឡូម៉ែតពី ស៊ីសុផុន-ប៉ោយប៉ែតខូចខាតទាំងស្រុងក្នុងឆ្នាំ ១៩៧០ ដោយសារសង្គ្រាមស៊ីវិល។ ការស្តាបនាខ្សែផ្លូវដែកភាគខាងជើងត្រូវបានចាប់ផ្តើមនៅឆ្នាំ ១៩២៩ និងបានបញ្ចប់ក្នុងឆ្នាំ ១៩៤២[32]។

តារាងទី ២៖ បង្ហាញពីប្រវត្តិនៃការសាងសង់ខ្សែខាងជើង

| ឆ្នាំ | ចំណុច | ប្រវែង(គីឡូម៉ែត្រ) |
|---|---|---|
| ១៩២៩-១៩៣១ | ភ្នំពេញ - ពោធិ៍សាត់ | ១៦៥.៥ |
| ១៩៣១-១៩៣២ | ពោធិ៍សាត់ - បាត់ដំបង | ១០៧.៦ |

[29] គេហទំព័រក្រសួងសាធារណការ និងដឹកជញ្ជូន, "សេវាដឹកជញ្ជូនផ្លូវដែក", http://www.mpwt.gov.kh/kh/public-services/railway-services

[30] Ibid

[31] Ibid

[32] ADB Report, "Cambodia: Preparing the Greater Mekong Subregion: Rehabilitation of the Railway in Cambodia", ឆ្នាំ ២០០៦

| | | |
|---|---|---|
| ១៩៣២-១៩៣៣ | បាត់ដំបង - មង្គលបុរី | ៥៧.១ |
| ១៩៣៣-១៩៤២ | មង្គលបុរី - ប៉ោយប៉ែត | ៥៥.៨ |

ប្រភពពី៖ ADB technical Assistance Consultant's Report, Cambodia: Preparing the Greater Mekong Sub region: Rehabilitation of the Railway in Cambodia

ខ្សែផ្លូវខាងត្បូងត្រូវបានចាប់ផ្តើមនៅដើមទសវត្សរ៍ឆ្នាំ ១៩៦០ ហើយវាបានបើកដំណើរការសម្រាប់ឆ្នាំ ១៩៦៩ មុនពេលចាប់ផ្តើមសង្គ្រាមស៊ីវិល។ ខ្សែនេះភ្ជាប់ពីក្រុងភ្នំពេញទៅក្រុងព្រះសីហនុមានប្រវែងសរុប ២៦៤ គីឡូម៉ែត្រ។

តារាងទី ៣ ៖ បង្ហាញពីប្រវត្តិនៃការសាងសង់ខ្សែខាងត្បូង

| ឆ្នាំ | ចំណុច | ប្រវែង(គីឡូម៉ែត្រ) |
|---|---|---|
| ១៩៦០-១៩៦៦ | ភ្នំពេញ - តាកែវ | ៧៤.៥ |
| ១៩៦៦-១៩៦៧ | តាកែវ - កំពត | ៩១.៥ |
| ១៩៦៧-១៩៦៩ | កំពត - ក្រុងព្រះសីហនុ | ៩៨ |

ប្រភពពី៖ ADB technical Assistance Consultant's Report, Cambodia: Preparing the Greater Mekong Sub region: Rehabilitation of the Railway in Cambodia.

### ២.១.២ ផ្លូវដែកមុនឆ្នាំ ១៩៧០

ខ្សែបន្ទាត់ទីមួយឬ " ខ្សែចាស់" ត្រូវបានគេសាងសង់ចន្លោះឆ្នាំ ១៩២៩ និងឆ្នាំ ១៩៤២។ ការកសាងនេះក្រោមការគ្រប់គ្រងរបស់បារាំង ពោលពីភ្នំពេញទៅប៉ោយប៉ែត និងភ្ជាប់ពីកម្ពុជាដល់ព្រំដែនថៃដោយឆ្លងកាត់ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបងដែលមានប្រវែងសរុប ៣៨៦ គីឡូម៉ែត្រ[33]។ ខ្សែខាងជើងត្រូវបានកសាងដោយប្រើកំណល់ទ្រជើងទម្ងន់ ៣០ គីឡូក្រោមក្នុងមួយម៉ែត្រ។ ការកសាងអាចមានសមត្ថភាពដឹកទំនិញធុនធ្ងន់ពី ១៣ ទៅ ១៥តោន។ ខ្សែខាងជើងមានស្ថានីយចំនួន ៤៩កន្លែង។ បន្ថែមពីលើនេះ ខ្សែរថភ្លើងបានភ្ជាប់ពីរាជធានីភ្នំពេញទៅទីក្រុងបាងកកក្នុងអំឡុងឆ្នាំ ១៩៤២-១៩៦១[34]។

ខ្សែបន្ទាត់ខាងត្បូងឬ "ខ្សែថ្មី" ពីភ្នំពេញទៅកំពង់ផែក្រុងព្រះសីហនុប្រវែង ២៦៤ គីឡូម៉ែត្រដែលឆ្លងកាត់ ខេត្តតាកែវ និងខេត្តកំពត (ភ្នំពេញ-តាកែវ ៧៥ គីឡូម៉ែត្រ, តាកែវ-កំពត

[33] Chap Moly, "Infastructure Development of Railway in Cambodia: A Long Term Strategy" ឆ្នាំ ២០០៨

[34] Ibid

៩២ គីឡូម៉ែត្រ និងកំពត-ព្រះសីហនុ ៩៨ គីឡូម៉ែត្រ)[35]។ ខ្សែរថភ្លើងនេះត្រូវបានកសាងឡើង អំឡុងឆ្នាំ ១៩៦០ និងឆ្នាំ ១៩៦៩ ដោយមានជំនួយពីប្រទេសបារាំង អាល្លឺម៉ង់ខាងលិច និង ប្រទេសចិន។ ខ្សែបន្ទាត់ភាគខាងត្បូងត្រូវបានសាងសង់ដោយប្រើកំណល់ទ្រជើងទម្ងន់ ៤៣ គីឡូក្រាមក្នុងមួយម៉ែត្រ និងមានស្ថានីយចំនួន ២៨កន្លែង[36]។

ក្នុងឆ្នាំ ១៩៦៩-១៩៧០ មានរថភ្លើងចំនួន ៣៧ ជើងក្នុងមួយថ្ងៃដោយមានក្បាលម៉ាស៊ីន ប្រើប្រាស់ចំនួន ៧៤ គ្រឿង និងទូរថភ្លើងគ្រប់ប្រភេទចំនួន ៩២៨ទូ ហើយរថភ្លើងមានល្បឿន ៦០ គីឡូម៉ែត្រក្នុងមួយម៉ោង[37]។

### ២.១.៣ ផ្លូវដែកចាប់ពីឆ្នាំ ១៩៧០-១៩៧៩

ក្រោយឆ្នាំ ១៩៧០ ប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងបញ្ហានយោបាយ និងបានធ្លាក់ចូល ទៅក្នុងសង្គ្រាមស៊ីវិល។ ជាពិសេសនៅឆ្នាំ ១៩៧៥-១៩៧៩ កម្ពុជាទាំងមូលដែលស្ថិតក្រោមរបប គ្រប់គ្រងខ្មែរក្រហមដ៏ឃោរឃៅដែលបានធ្វើឲ្យកម្ពុជាធ្លាក់ដល់ចំណុចសូន្យ។ នៅពេលនោះរថភ្លើង ប្រើសម្រាប់តែយោធាតែប៉ុណ្ណោះ[38]។

### ២.១.៤ ផ្លូវដែកចាប់ពីឆ្នាំ ១៩៨១-១៩៩៨

ទោះបីជាជម្លោះស៊ីវិល ការគំរាមកំហែងដោយគ្រាប់មីន និងការគំរាមកំហែងដោយធម្មជាតិ ក៏ដោយ ការដឹកជញ្ជូនតែមាននឹងត្រូវការជាចាំបាច់ក្នុងអំឡុងឆ្នាំ ១៩៨១-១៩៩៨។ កាន់តែគួរឲ្យ កត់សម្គាល់ ផ្លូវដែកកម្ពុជាស្ថិតនៅក្រោមស្ថានភាពលំបាកដោយសារគ្រោះថ្នាក់ ពោលគឺដោយ សារគ្រាប់មីន និងជម្លោះស៊ីវិលបន្ទាប់ពីរយៈពេលប្រហែលជាង ២០ ឆ្នាំហើយផ្លូវដែកទាំងពីរខ្សែ ត្រូវបានរងការខូចខាតយ៉ាងធ្ងន់ធ្ងរនៅផ្នែកមួយចំនួនដែលត្រូវបានបំផ្លាញ[39]។

ក្នុងអំឡុងពេលនោះក្បាលរថភ្លើង(ម៉ាស៊ូត) ដែលប្រើប្រាស់បានមានចំនួន ២៩គ្រឿង និង ទូរថភ្លើងមានចំនួន ៤៨ទូ។ ហេដ្ឋារចនាសម្ព័ន្ធនៃផ្លូវដែកចាស់ៗត្រូវបានខូចខាត ត្រូវបានគេធ្វើ ការជួសជុលបន្តិចបន្តួច។ ម្យ៉ាងវិញទៀតផ្លូវរថភ្លើងតាំងពីដំបូងមកមិនបានធ្វើថ្មី ឬកែលម្អឲ្យ ប្រសើរជាងមុនទេ ពោលគឺអាចដឹកបានត្រឹមតែ ១០តោនប៉ុណ្ណោះនៅក្រោយឆ្នាំ១៩៧០ ហើយមាន

[35] Chap Moly, "Infastructure Development of Railway in Cambodia: A Long Term Strategy" ឆ្នាំ ២០០៨

[36] Ibid

[37] Ibid

[38] Ibid

[39] Ibid

រថភ្លើងជាច្រើនដែលមានអាយុកាលរហូតដល់ ៦០ឆ្នាំ ឬច្រើនជាងនេះទៅទៀត។ ឆ្នាំ១៩៩៧ នៅលើខ្សែបន្ទាត់ខាងជើងមានស្ពានចំនួន ១៧៥ កន្លែង និងលូបូមទឹក ២៥២កន្លែងដែលមានសភាពទ្រុឌទ្រោមដោយហេតុនេះហើយទើបមានការកំណត់ល្បឿនត្រឹម ១០-១៥ គីឡូម៉ែត្រក្នុងមួយម៉ោងប៉ុណ្ណោះនៅកន្លែងមានស្ពាន[40]។ ខ្សែភាគខាងជើង ៤៨គីឡូម៉ែត្រ (កំណាត់ផ្លូវពីស៊ីសុផុន ទៅព្រំដែនថៃ) ត្រូវបានកាត់ផ្តាច់ទាំងស្រុង។ ចំណែកឯខ្សែបន្ទាត់ភាគខាងត្បូងវិញក៏ស្ថិតនៅក្នុងស្ថានភាពមិនល្អដែរ គឺជួសជុលបណ្តោះអាសន្នឡើងវិញក្នុងគោលបំណងដឹកទំនិញនឹងរំពឹងថាអាចផ្ទុកទំនិញទម្ងន់ ២០ តោន ប៉ុន្តែក្នុងស្ថានភាពជាក់ស្តែងបានត្រឹមតែ ១៥ តោនប៉ុណ្ណោះ។ មួយវិញទៀតហេដ្ឋារចនាសម្ព័ន្ធត្រូវបានខូចខាតដោយសារគ្រាប់មីន និងទឹកជំនន់ ៧០% ហើយកំណល់ទ្រជើងត្រូវបានជួសជុលឡើងវិញស្ទើរតែទាំងស្រុង ស្ពានចំនួន ១៦កន្លែង (១៧.២%) និងលូបូមទឹកនៅតាមបណ្តោយផ្លូវរថភ្លើង ប្រវែង ៥៦៦.៦៦ម៉ែត្រត្រូវបានបំផ្លាញដោយទឹកជំនន់ និងស្ថានីយចំនួន ២៤ (៨៥.៧១%) ត្រូវបានខូចខាត[41]។ ក្នុងអំឡុងពេលនោះគេអាចនិយាយបានថា ផ្លូវដែករបស់កម្ពុជាធ្វើការទំនាក់ទំនងដោយប្រើវិទ្យុទាក់ទងដើម្បីផ្តល់ដំណឹងឲ្យទៅស្ថានីយធំតែមួយប៉ុណ្ណោះ[42]។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយសេវាកម្មផ្លូវរថភ្លើងអាចធ្វើចរាចរបន្តិចបន្តួចនៅដើមទសវត្សរ៍ឆ្នាំ ១៩៨០[43]។

តារាងទី ៤ ៖ បង្ហាញពីទិន្នន័យនៃការដឹកជញ្ជូនតាមផ្លូវដែក (ឆ្នាំ ១៩៨១-១៩៩៨)

| ឆ្នាំ | ខ្សែខាងជើង | ខ្សែខាងត្បូង | សរុប |
|---|---|---|---|
| ១៩៨១ | ២១,២០០ | ៦២,៦០០ | ៨៣,៨០០ |
| ១៩៨៥ | ៩៥,៤០០ | ៥៣,៤០០ | ១៤៨,៨០០ |
| ១៩៨៩ | ៧៤,០០០ | ៦៥,៦០០ | ១៣៩,៦០០ |
| ១៩៩០ | ៦៤,៣០០ | ៥១,០០០ | ១១៥,៣០០ |
| ១៩៩១ | ៣៨,០០០ | ២៦,៤០០ | ៦៤,៤០០ |
| ១៩៩២ | ៩០,៨០០ | ២៣,៧០០ | ១១៤,៥០០ |

40 Chap Moly, "Infastructure Development of Railway in Cambodia: A Long Term Strategy" ឆ្នាំ ២០០៨

41 Ibid

42 Ibid

43 Ibid

| | | | |
|---|---|---|---|
| ១៩៩៣ | ១១៤,២០០ | ១៥,៦០០ | ១២៩,០០០ |
| ១៩៩៤ | ៤៨,២០០ | ១២,៦០០ | ៦០,៨០០ |
| ១៩៩៥ | ៣៣,២៩០ | ១៦,៥០០ | ៤៩,៧៩០ |
| ១៩៩៦ | ៥០,១៨០ | ២៥,៨០៧ | ៧៥,៩៨៧ |
| ១៩៩៧ | ១០២,៣៣៤ | ៦៧,៤១៩ | ១៦៩,៧៥៣ |
| ១៩៩៨ | ២០៨,០១០ | ៨៦,៤៤១ | ២៩៤,៤៥១ |

ប្រភពពី៖ Infastructure Development of Railway in Cambodia: A Long Term Strategy˝ ឆ្នាំ ២០០៨

ដូចដែលបានបង្ហាញក្នុងតារាងខាងលើនេះការដឹកជញ្ជូនតាមផ្លូវដែកចាប់ផ្តើមមានសកម្មភាពងើបឡើងវិញក្រោយពីសង្គ្រាមដោយមានកំណើនបន្តិចម្តងៗ ដែលក្នុងឆ្នាំ១៩៨១ មានចំនួនសរុបដឹកជញ្ជូនទាំងពីរខ្សែ ៨៣,៨០០តោន បើធៀបនឹងឆ្នាំ១៩៩៨ ការដឹកជញ្ជូនទំនិញមានការកើនឡើងដល់ ២៩៥,៤៥១តោន។

ក្រាហ្វិកទី ១ ៖ បង្ហាញពីទំហំនៃការដឹកជញ្ជូន (១៩៨១-១៩៩៨) គិតជាតោន




**២.១.៥ ផ្លូវដែកចាប់ពីឆ្នាំ ១៩៩៨-២០០៥**

ផ្លូវដែកត្រូវបានជួសជុលឡើងវិញ ប៉ុន្តែនៅស្ថិតក្នុងស្ថានភាពទ្រុឌទ្រោមដដែល ដូច្នេះហើយផ្លូវដែកអាចរត់ល្បឿនត្រឹមតែ ២០ ទៅ ៣០គីឡូម៉ែត្រក្នុងមួយម៉ោងប៉ុណ្ណោះ។ បន្ថែមពីលើ

នេះទៀតសេវាកម្មនៃការដឹកជញ្ជូនមួយខ្សែអាចដឹកបានត្រឹមតែមួយជើងប៉ុណ្ណោះក្នុងមួយថ្ងៃ[44]។ ជាក់ស្តែងការធ្វើចរាចរណ៍ផ្លូវដែកមានទំហំតិចជាងមុនពេលសង្គ្រាមទៅទៀតពោលគឺមិនសូវមានរីកចម្រើនប៉ុន្មានទេ។

បើគិតចាប់តាំងពីក្រោយឆ្នាំ១៩៩៨ មកដល់បច្ចុប្បន្នរថភ្លើងរបស់កម្ពុជាអាចដឹកទំនិញចម្បងៗមួយចំនួនតែប៉ុណ្ណោះនោះគឺៈ ប្រេងសាំង, ស៊ីម៉ង់, ជីធម្មជាតិ, កុងតឺន័រ, សម្ភារៈសំណង់, ផលិតផលកសិកម្ម, អង្ករ, ស្ករ, និងទំនិញផ្សេងៗទៀត។

តារាងទី ៥ ៖ បង្ហាញពីឈ្មោះក្រុមហ៊ុន និងប្រភេទដែលប្រើប្រាស់ការដឹកជញ្ជូនតាមផ្លូវដែក

| លេខ | ឈ្មោះក្រុមហ៊ុនដឹកទំនិញ | ប្រភេទទំនិញ |
|---|---|---|
| ១ | SOKIMEX | ប្រេងសាំង |
| ២ | CALTEX | ប្រេងសាំង |
| ៣ | RTC | ស៊ីម៉ង |
| ៤ | Hour Hout | ទំនិញធុនធ្ងន់ |
| ៥ | Lim Hour | ស៊ីម៉ង |
| ៦ | Master Railway Transport | កុងតឺន័រ |
| ៧ | Lim | ផលិតផលកសិកម្ម |

ប្រភពពីៈ Infastructure Development of Railway in Cambodia: A Long Term Strategy ឆ្នាំ ២០០៨

បន្ថែមពីលើពីនេះមានតែក្រុមហ៊ុនធំៗចំនួន ៧ ប៉ុណ្ណោះដែលបានសម្រេចចិត្តដឹកទំនិញតាមរថភ្លើងដែលមានដូចជា ក្រុមហ៊ុន SOKIMEX និង CALTEX ដែលប្រើប្រាស់សេវាដឹកជញ្ជូនតាមផ្លូវដែកសម្រាប់ដឹកប្រេងសាំង។ ក្រុមហ៊ុន R.T.C. COMPANY LIMITED និង ក្រុមហ៊ុន Lim Hour ដែលបានដឹកជញ្ជូនស៊ីម៉ងតាមផ្លូវដែក។ ក្រុមហ៊ុន Hour Hout ដឹកទំនិញធុនធ្ងន់និងក្រុមហ៊ុនផ្សេងៗទៀត។

ខាងក្រោមនេះជាទិន្នន័យបានពីការដឹកជញ្ជូនពីឆ្នាំ ១៩៩៨ រហូតដល់ ឆ្នាំ២០០៥ ដោយបង្ហាញពីទំហំសរុបនៃផ្លូវដែកទាំង២ខ្សែដែលបានធ្វើចរាចរ។

តារាងទី ៦ ៖ បង្ហាញពីទំហំនៃការដឹកជញ្ជូនខ្សែខាងជើង និងត្បូង (១៩៩៨-២០០៥) គិតជាតោន

[44] Chap Moly, "Infastructure Development of Railway in Cambodia: A Long Term Strategy" ឆ្នាំ ២០០៨

| ឆ្នាំ | ខ្សែខាងជើង | ខ្សែខាងត្បូង | សរុប |
|---|---|---|---|
| **១៩៩៨** | ២០៨,០១០ | ៨៦,៨៤១ | ២៩៤,៨៥១ |
| **១៩៩៩** | ១៨៩,២៧០ | ៧៩,១២២ | ២៦៨,៣៩២ |
| **២០០០** | ១៣៧,៤៨៤ | ២០២,៦៧២ | ៣៤០,១៥៦ |
| **២០០១** | ២០១,៤៥២ | ២០៨,២៥១ | ៤០៩,៧០៣ |
| **២០០២** | ៣៥៣,៦៥៤ | ២០៣,៦៥៣ | ៥៥៧,៣០៧ |
| **២០០៣** | ១២២,៥០៨ | ៣០០,១៩២ | ៤២២,៧០០ |
| **២០០៤** | ៨៥,៣៥២ | ២១១,៨៦៥ | ២៩៧,២១៧ |
| **២០០៥** | ១៧៤,០០៥ | ៩៤,៧៩៥ | ២៦៨,៨០០ |

ប្រភពពី៖ Infastructure Development of Railway in Cambodia: A Long Term Strategy˝ ឆ្នាំ ២០០៨

ក្រាហ្វិកទី ២៖ បង្ហាញពីទំហំនៃការដឹកជញ្ជូន (១៩៩៨-២០០៥) គិតជាតោន




ដូចដែលបានបង្ហាញក្នុងក្រាហ្វិកខាងលើ ការដឹកជញ្ជូនតាមផ្លូវដែកបានមានសកម្មភាពដើបឡើងវិញបន្តិចបន្តួច តែទោះយ៉ាងណាក្តីបើយោងតាមទិន្នន័យដែលបានបង្ហាញដោយនាយកដ្ឋានផ្លូវដែកបានឲ្យឃើញថា តាំងពីឆ្នាំ១៩៩៨ មានការកើនឡើងវិញជាបណ្តើរៗនូវសកម្មភាពនៃការដឹកជញ្ជូនតែកំណើននេះមិនបានយូរអង្វែងប៉ុន្មានទេ ពោលគឺមានការធ្លាក់ចុះមកវិញនៅក្នុងឆ្នាំ២០០៥។ មានន័យថា នៅក្នុងឆ្នាំ១៩៩៨ ចំនួនទិន្នន័យដែលបានដឹកជញ្ជូន

មានចំនួន ២៩៩,៩៥១តោន ហើយធ្លាក់ចុះមកវិញនៅត្រឹមតែ ២៦៨,៨០០តោនក្នុងឆ្នាំ២០០៥។ ការដឹកជញ្ជូនតាមរយៈផ្លូវដែកនៅក្នុងប្រទេសកម្ពុជាមានកំណើនឡើងវិញគួរឲ្យកត់សម្គាល់ដោយ នៅក្នុងឆ្នាំ២០០២ ដែលទិន្នន័យសរុបមានចំនួន ៥៥៧,៣០៧តោន ក្នុងនោះខ្សែខាងជើងបានចូលរួមចំណែករហូតដល់ ៣៥៣,៦៥៤តោន រីឯខ្សែខាងត្បូងចូលរួមចំណែករហូតដល់ ២០៣,៦៥៣តោន។ បន្ទាប់មកបានធ្លាក់ចុះមកវិញនៅឆ្នាំ ២០០៥ ដោយចុះមកត្រឹម ២៦៨,៨០០ តោន។ មូលហេតុនៃការធ្លាក់ចុះក្នុងដំណើរការនៃការដឹកទំនិញតាមផ្លូវដែកក្នុងឆ្នាំ ២០០៥ មាន ២ ចំណុចដូចជា[45]៖

ក.ការប្រកួតប្រជែងពីផ្លូវជាតិ

មានមូលហេតុជាច្រើនដែលធ្វើការដឹកជញ្ជូនទំនិញតាមរយៈផ្លូវដែកធ្លាក់ចុះ ម្យ៉ាងគឺដោយសារតែមានការប្រកួតប្រជែងពីផ្លូវជាតិ នោះដោយសាររាជរដ្ឋាភិបាលមានការអភិវឌ្ឍន៍ផ្លូវជាតិដោយបង្កើនចរាចរណ៍នៅលើផ្លូវជាតិ។ ផ្លូវជាតិលេខ ៥ ត្រូវបានកសាងឡើងវិញហើយបានដើរតួនាទីជំនួសឲ្យផ្លូវដែកខ្សែខាងជើង និងផ្លូវជាតិលេខ ២ ផ្លូវជាតិលេខ ៣ ផ្លូវជាតិលេខ ៤ បានកសាងឡើងវិញហើយវាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជំនួសផ្លូវដែកខ្សែខាងត្បូង។

- ផ្លូវជាតិលេខ៥ បានជួសជុលឡើងវិញជាបន្ទាន់ បន្ទាប់ពីទទួលបានជំនួយពី UNDP ក្នុងឆ្នាំ ១៩៩២-១៩៩៣ និងជួសជុលសម្រេចក្នុងឆ្នាំ ២០០៥ ក្រោមជំនួយរបស់ប្រទេសថៃ រួមនឹង UNDP។ បន្ថែមពីលើនេះទៀតស្ពាននៅតាមបណ្ដោយផ្លូវជាតិលេខ ៥ និងលេខ ៦ ក៏បានជួសជុលឡើងវិញក្រោមថវិកាគាំទ្ររបស់ ADB ផងដែរក្នុងឆ្នាំ ២០០៦-២០០៨
- ផ្លូវជាតិលេខ២ ទទួលបានជំនួយពីប្រទេសជប៉ុនដើម្បីជួសជុលឡើងវិញក្នុងឆ្នាំ ២០០២-២០០៣
- ផ្លូវជាតិលេខ៣ និង៤ តាំងពីឆ្នាំ ២០០២-២០០៤ ទទួលបានជំនួយពី WB[46]។

ខ.ការទ្រុឌទ្រោមនៃក្បាលម៉ាស៊ីនរថភ្លើង

មូលហេតុមួយទៀតដែលនាំឲ្យការដឹកជញ្ជូនតាមរយៈផ្លូវដែកមានការធ្លាក់ចុះគឺកង្វះខាតអ្នកជំនាញផ្លូវដែក និងជំនាញជួសជុលក្បាលរថភ្លើងជាបញ្ហាចម្បងដែលធ្វើឲ្យស្ថានភាពផ្លូវដែកនៅកម្ពុជាមិនទទួលបានការដំណើរការល្អ។ នៅដែលមានបញ្ហាទៅលើផ្នែកទាំងនេះម្តងៗ គេ

[45] Chap Moly, "Infastructure Development of Railway in Cambodia: A Long Term Strategy" ឆ្នាំ ២០០៨

[46] Ibid

តែងតែពឹងពាក់អ្នកជំនាញរបស់ប្រទេសបារាំងមកដោះស្រាយ ដោយចំណាយថវិកាច្រើន។ ម្យ៉ាងវិញទៀតដោយសារតែផ្លូវដែក, ក្បាលរថភ្លើង និងទូរថភ្លើងរបស់កម្ពុជាខូចខាតច្រើនទើបបណ្តាលឲ្យមានការធ្លាក់ចុះនៃការដឹកជញ្ជូនក្នុងឆ្នាំ២០០៥[47]។

## ២.២ ការជួសជុលឡើងវិញ

### ២.២.១ ការជួសជុលអំឡុងឆ្នាំ ១៩៩៣-១៩៩៥

ដោយសារការដឹកជញ្ជូនដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមក្រោមការដឹកនាំរបស់រដ្ឋាភិបាល និងក្រសួងសាធារណការ និងដឹកជញ្ជូន ផ្លូវដែកកម្ពុជាបានទទួលជំនួយសម្រាប់ការស្តារឡើងវិញនូវខ្សែទាំងពីរដែលបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩៣ ដែលបានជំនួយហិរញ្ញវត្ថុពីរដ្ឋាភិបាលបារាំងជាមួយជំនួយពី ADB។ គម្រោងនោះគឺជាគម្រោងជំនួយលើការស្តារផ្លូវដែកឡើងវិញ ពិសេសការអនុវត្តគម្រោងក្នុងវិស័យដឹកជញ្ជូនដោយទទួលបានឥណទានពី ADB (ADB-1199-CAM)[48]។ គម្រោងនេះបានចាប់ផ្តើមពីឆ្នាំ ១៩៩៣ និងបញ្ចប់នៅឆ្នាំ ១៩៩៥ លើការស្តារឡើងវិញដល់ផ្នែកផ្លូវដែកនៅតាមបណ្តាស្ពាន, ជួសជុលប្រព័ន្ធបង្ហូរទឹកតាមបណ្តោយផ្លូវដែកទាំងនោះ និងការជួសជុលស្ថានីយនៅភ្នំពេញ។ ខ្សែទាំងពីរនេះគ្រាន់តែត្រូវបានជួសជុលបណ្តោះអាសន្នប៉ុណ្ណោះសម្រាប់សេវាកម្មអំឡុងពេលនោះ។ ការស្តារនេះមិនមែនត្រឹមតែត្រូវការជំនួយសម្រាប់ស្តារផ្លូវដែកបណ្តោះអាសន្ននោះទេ ប៉ុន្តែក៏ត្រូវការចាំបាច់សម្រាប់ការស្តាររយៈពេលវែងដើម្បីការធ្វើឲ្យផ្លូវដែកកាន់តែរឹងមាំ និងមានប្រសិទ្ធិភាពសម្រាប់ការដឹកជញ្ជូន។ នៅពេលនោះរាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តផែនការសកម្មភាពដើម្បីធ្វើកំណែទម្រង់ជួសជុល និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវដែក។ ផែនការនេះរួមបញ្ចូលទាំងការកែទម្រង់រចនាសម្ព័ន្ធ ការស្តារឡើងវិញនៃខ្សែរថភ្លើងដែលមានស្រាប់[49]។

### ២.២.២ ការជួសជុលអំឡុងឆ្នាំ ២០០១-២០០៣

ការអនុវត្តគម្រោងក្រោមជំនួយឥណទានរបស់ធនាគារអភិវឌ្ឍអាស៊ី ADB ដែលមានលេខ ADB Loan No.1824-CAM(SF) ដោយសារមានគ្រោះទឹកជំនន់ធ្វើឲ្យខូចខាតដល់ហេដ្ឋាសម្ព័ន្ធផ្លូវដែកនិងស្ពាន គម្រោងនេះបានស្តារផ្លូវដែកឡើងវិញចម្ងាយ ៣៥ គីឡូម៉ែត្រ, ប្រព័ន្ធបង្ហូរទឹកនៅ

---

[47] Chap Moly, "Infastructure Development of Railway in Cambodia: A Long Term Strategy" ឆ្នាំ ២០០៨

[48] Ibid

[49] Ibid

ខ្សែខាងជើង និងជួសជុលស្ពាននៅខ្សែខាងត្បូង[50]។

### ២.២.៣ ការជួសជុលអំឡុងឆ្នាំ ២០០៦-២០១០

ដោយជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍអាស៊ីដែលបានចាប់ផ្តើមនៅខែមករា ឆ្នាំ ២០០៦ ហើយត្រូវបានរំពឹងថានឹងបញ្ចប់នៅខែមីនាឆ្នាំ ២០០៨ កិច្ចព្រមព្រៀងប្រាក់កម្ចីនេះត្រូវបានចុះហត្ថលេខាកាលពីថ្ងៃទី ៥ ខែមីនា ឆ្នាំ២០០៧ ដោយរាជរដ្ឋាភិបាលកម្ពុជាសហការជាមួយអង្គការ OPEC និងធនាគារអភិវឌ្ឍអាស៊ីក្នុងតម្លៃ ៧៣ លានដុល្លារអាមេរិកសម្រាប់ការស្តារឡើងវិញនៃផ្លូវដែក (ធនាគារអភិវឌ្ឍន៍អាស៊ីផ្តល់ ៤២ លានដុល្លារអាមេរិក, ១៣លានដុល្លារអាមេរិកទៀតដោយអង្គការ OPEC, រដ្ឋាភិបាលកម្ពុជា ១៥,២ លានដុល្លារអាមេរិក និងរដ្ឋាភិបាលម៉ាឡេស៊ីផ្តល់ជំនួយជាដែកដែលមានតម្លៃស្មើនឹង ២,៨ លានដុល្លារអាមេរិក)។ គម្រោងនេះត្រូវបានបញ្ចប់នៅឆ្នាំ ២០១០[51]។

គម្រោងនេះនឹងស្តារហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកកម្ពុជាឡើងវិញដោយការស្តារផ្លូវដែកដែលមានស្រាប់។ ប្រតិបត្តិការនេះ គឺការកែលម្អតាមរយៈការរៀបចំហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការដំណើរការផ្លូវដែកប្រកបដោយប្រសិទ្ធភាពដល់វិស័យដឹកជញ្ជូនដូចជាបង្កើនសមត្ថភាពប្រកួតប្រជែងនៃផ្លូវដែក, កាត់បន្ថយការខូចខាតផ្លូវ និងគ្រោះថ្នាក់ចរាចរណ៍ដែលពាក់ព័ន្ធនឹងការដឹកជញ្ជូនទំនិញធុនធ្ងន់។ លទ្ធផលនៃការស្តារ និងជួសជុលក្នុងគម្រោងនេះបានសម្រេចសមិទ្ធផលដូចជា[52]៖

- ហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកប្រហែល ៦០០ គីឡូម៉ែត្រដែលរួមមានផ្លូវរថភ្លើងនិងស្ពានដែលរងការខូចខាតនៅតាមបណ្តាខ្សែខាងត្បូងនិងខាងជើងអាចមានប្រតិបត្តិការសុវត្ថិភាពនៅល្បឿនអតិបរមា ៥០ គីឡូម៉ែត្រក្នុងមួយម៉ោង។
- ខ្សែរថភ្លើងដែលមានប្រវែង ១១០ គីឡូម៉ែត្ររវាងសំរោងនិងទូកមាសត្រូវបានបើកឲ្យដំណើរការនៅខែតុលាឆ្នាំ ២០១០ ។
- ផ្លូវដែលតភ្ជាប់ពីស៊ីសុផុនទៅប៉ោយប៉ែតប្រវែង ៤៨ គីឡូម៉ែត្របានបញ្ចប់ប្រហែល ៤២ គីឡូម៉ែត្រ។

---

50 ADB Report, "Cambodia: Preparing the Greater Mekong Subregion: Rehabilitation of the Railway in Cambodia", ឆ្នាំ ២០០៦

51 Chap Moly, "Infastructure Development of Railway in Cambodia: A Long Term Strategy" ឆ្នាំ ២០០៨

52 Ibid

- គម្រោងថវិកានេះបានដោះស្រាយផលប៉ះពាល់ ៣,៨១២ គ្រួសារដែលក្នុងនោះ ១,០៣៥ គ្រួសារត្រូវបានរងផលប៉ះពាល់យ៉ាងពេញលេញ និងតម្រូវឲ្យមានការផ្លាស់ប្តូរទីលំនៅ។ ដំណោះស្រាយបញ្ហានេះបានបញ្ចប់នៅក្នុងឆ្នាំ ២០១៥[53]។

### ២.២.៤ ការជួសជុលអំឡុងឆ្នាំ ២០០៩-២០១៤

គម្រោងស្តារ និងអភិវឌ្ឍផ្លូវដែកមួយទៀតដែលមានឈ្មោះថា "អនុតំបន់ទន្លេមេគង្គៈ គម្រោងស្តារផ្លូវដែកកម្ពុជាឡើងវិញ" ផែនការនេះនឹងអាចបង្កើតនូវឱកាសអភិវឌ្ឍដ៏យូរអង្វែងនៅប្រទេសកម្ពុជាក្នុងវិស័យសេវាកម្មដឹកជញ្ជូនដើម្បីពង្រីកបណ្តាញច្រកសេដ្ឋកិច្ចរបស់មហាអនុតំបន់ទន្លេមេគង្គតាមរយៈតំណភ្ជាប់ជាមួយប្រទេសជិតខាង។ គម្រោងស្តារផ្លូវដែកកម្ពុជាក្នុងអនុតំបន់ទន្លេមេគង្គនេះកើតឡើងក្រោមជំនួយឧបត្ថម្ភពីរដ្ឋាភិបាលអូស្ត្រាលីក្នុងទំហំទឹកប្រាក់ប្រមាណជាង ២២លានដុល្លារអាមេរិក បូករួមទាំងមូលនិធិ ADB ក្នុងទំហំទឹកប្រាក់ ៤២លានដុល្លារអាមេរិក (សរុបទឹកប្រាក់ប្រមាណ ៦៤លានដុល្លារអាមេរិក)[54]។ សមិទ្ធិផលពីគម្រោងអភិវឌ្ឍនេះបានសម្រេចនូវលទ្ធផលជាច្រើនរួមមាន[55]៖

- បង្កើតកន្លែងថែទាំស្តុកទំនិញដឹកជញ្ជូននៅសំរោងដែលមានចម្ងាយ ១០ គីឡូម៉ែត្រភាគខាងលិចរាជធានីភ្នំពេញដោយមានទំហំគ្រប់គ្រាន់ដើម្បីបំពេញតម្រូវការដឹកជញ្ជូននៅពេលអនាគត
- ពង្រឹងប្រព័ន្ធព័ត៌មាននៅស្ថានីយ ដើម្បីកាន់តែផ្តល់ភាពងាយស្រួលដល់ខ្សែរថភ្លើងដែលធ្វើដំណើរការ
- ការស្តារ និងតភ្ជាប់ផ្លូវដែកភ្ជាប់ជារវាងប្រទេសកម្ពុជា និងប្រទេសថៃ
- គ្រួសារដែលទទួលរងផលប៉ះពាល់រស់នៅជិតផ្លូវរថភ្លើង និងស្ថានីយត្រូវបានទទួលសំណងសមរម្យ។

## ២.៣ ស្ថានភាពផ្លូវដែក និងការដឹកជញ្ជូនបច្ចុប្បន្នរបស់ផ្លូវដែកកម្ពុជា

បច្ចុប្បន្នផ្លូវដែកទាំងពីរខ្សែ ត្រូវបានសាងសង់ និងជួសជុលដាក់ឲ្យប្រើប្រាស់ឡើងវិញតាមរយៈការសហការរវាងក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រុមហ៊ុន RRC ដែលធ្វើ

---

[53] ADB Report, "Cambodia: CAM: GMS Rehabilition of the Railway in Cambodia", Project number 37269-013

[54] ADB Report, "Cambodia: Greater Mekong Subregion: Rehabilitition of the Railway in Cambodia Project", Project number 37269-023

[55] Ibid

ប្រតិបត្តិការដឹកទំនិញ និងដឹកជញ្ជូនអ្នកដំណើរដូចខាងក្រោម៖

### ២.៣.១ ផ្លូវដែកភាគខាងត្បូង (ភ្នំពេញ-ព្រះសីហនុ)

ដើម្បីលើកស្ទួយការដឹកជញ្ជូនប្រកបដោយប្រសិទ្ធភាពព្រមទាំងធ្វើឲ្យប្រសើរឡើងនូវបណ្តាញដឹកជញ្ជូនតាមផ្លូវដែក។ កំពង់ផែស្វយ័តក្រុងព្រះសីហនុបានសហការជាមួយក្រុមហ៊ុន RRC បង្កើតប្រព័ន្ធផ្លូវដែក និងទីលានផ្ទុកទំនិញកុងតឺន័រក្នុងបរិវេណកំពង់ផែដើម្បីឲ្យអតិថិជន ឬម្ចាស់ទំនិញអាចដឹកជញ្ជូនទំនិញទូទៅ ពោលគឺទំនិញកុងតឺន័រពីកំពង់ផែក្រុងព្រះសីហនុទៅភ្នំពេញ និងពីភ្នំពេញមកកំពង់ផែក្រុងព្រះសីហនុ។ ជាក់ស្តែង ក្នុងឆ្នាំ ២០១៤ បរិមាណកុងតឺន័រដឹកជញ្ជូនតាមផ្លូវដែកមានការកើនឡើងយ៉ាងឆាប់រហ័សរហូតដល់ជាង ១១,៦៦០កុងតឺន័រ ហើយក្នុងឆ្នាំ ២០១៥ បរិមាណមានការកើនឡើងជាង ២០,០៤៧កុងតឺន័រ ក្នុងរយៈពេល ២ខែចុងក្រោយនៃឆ្នាំ ២០១៦ បរិមាណដឹកជញ្ជូនបានកើនឡើង ២១,២៤៥កុងតឺន័រ[56]។ អាជ្ញាធរកំពង់ផែក្រុងព្រះសីហនុបានកត់ត្រាការនាំចេញអង្ករកើនឡើង ៨៥% នៅក្នុងឆ្នាំ ២០១៣ ដែលភាគច្រើនបានធ្វើដំណើរទៅកាន់កំពង់ផែតាមរយៈខ្សែរថភ្លើងខ្សែខាងត្បូង។ បរិមាណនៃការនាំចេញអង្ករក្នុងឆ្នាំ ២០១៤ ត្រូវបានរាយការណ៍ដោយសមាគមន៍អ្នកនាំចេញស្រូវអង្ករកម្ពុជាមានចំនួន ៣៨៧,០៦១តោន ហើយផ្លូវដែកបានទទួលការដឹកជញ្ជូន ១ភាគ៤ នៃចំនួននេះ (ប្រមាណ ៩៦,៧៦៥តោន) លើសពីនេះទៀតការដឹកជញ្ជូនទំនិញតាមផ្លូវដែកបានកាត់បន្ថយការដឹកទំនិញតាមឡានកុងតឺន័រស្ទើរតែ ៧០០ គ្រឿងធ្វើដំណើររៀងរាល់សប្តាហ៍ពីផ្លូវជាតិ[57]។

#### ២.៣.១.១ សេវាដឹកអ្នកដំណើរភាគខាងត្បូង

តារាងទី ៧ ៖ បង្ហាញពីតម្លៃសំបុត្រតាមទិសដៅនៅខ្សែខាងត្បូង

| ទិសដៅ | តម្លៃ |
|---|---|
| ភ្នំពេញ-ក្រុងព្រះសីហនុ / ក្រុងព្រះសីហនុ-ភ្នំពេញ | ៨ ដុល្លារ |
| ភ្នំពេញ-កំពត / កំពត-ភ្នំពេញ | ៧ ដុល្លារ |
| ភ្នំពេញ-តាកែវ / តាកែវ-ភ្នំពេញ | ៥ ដុល្លារ |
| ក្រុងព្រះសីហនុ-កំពត / កំពត-ក្រុងព្រះសីហនុ | ៥ ដុល្លារ |

[56] លិខិតលេខ ១១៧៨.ដ ចេញថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០១៩ របស់នាយកដ្ឋានផ្លូវដែកនៃក្រសួងសាធារណការ និងដឹកជញ្ជូន

[57] កំពង់ផែស្វយ័តក្រុងព្រះសីហនុ http://www.pas.gov.kh/page-category/sihanoukville-autonomous-port

| | |
|---|---|
| ក្រុងព្រះសីហនុ-តាកែវ / តាកែវ-ក្រុងព្រះសីហនុ | ៧ដុល្លារ |
| តាកែវ-កំពត / កំពត-តាកែវ | ៦ ដុល្លារ |

ប្រភពពីៈ Royal Railway Cambodia (RRC)

### ២.៣.១.២ តម្លៃផ្ញើយានជំនិះ

តារាងទី ៨ ៖ បង្ហាញពីតម្លៃនៃការដឹកយានជំនិះតាមរថភ្លើងនៅខ្សែខាងត្បូង

| **ប្រភេទ** | **តម្លៃ** |
|---|---|
| រថយន្ត | ១៥ ដុល្លារ |
| ម៉ូតូ | ៥ ដុល្លារ (ធម្មតា) ១០ ដុល្លារ (ធំ) |
| កង់ | ២ ដុល្លារ |

ប្រភពពីៈ Royal Railway Cambodia (RRC)

### ២.៣.១.៣ កាលវិភាគរថភ្លើងចេញដំណើរ

តារាងទី ៩ ៖ បង្ហាញពីថ្ងៃ និងម៉ោងចេញដំណើរនៅខ្សែខាងត្បូង

| ថ្ងៃចេញដំណើរ | ម៉ោង | គោលដៅ |
|---|---|---|
| រាល់ថ្ងៃសុក្រ | ០៧:០០ | ភ្នំពេញ ទៅ ក្រុងព្រះសីហនុ |
| រាល់ថ្ងៃសៅរ៍ | ០៧:០០ | ភ្នំពេញ ទៅ ក្រុងព្រះសីហនុ |
| រាល់ថ្ងៃសៅរ៍ | ០៧:០០ | ក្រុងព្រះសីហនុ ទៅ ភ្នំពេញ |
| រាល់ថ្ងៃអាទិត្យ | ០៧:០០ | ភ្នំពេញ ទៅ ក្រុងព្រះសីហនុ |
| រាល់ថ្ងៃអាទិត្យ | ០៧:០០ | ក្រុងព្រះសីហនុ ទៅ ភ្នំពេញ |
| រាល់ថ្ងៃអាទិត្យ | ១៦:០០ | ភ្នំពេញ ទៅ ក្រុងព្រះសីហនុ |
| រាល់ថ្ងៃអាទិត្យ | ១៦:០០ | ក្រុងព្រះសីហនុ ទៅ ភ្នំពេញ |
| រាល់ថ្ងៃច័ន្ទ | ០៧:០០ | ក្រុងព្រះសីហនុ ទៅ ភ្នំពេញ |

ប្រភពពីៈ Royal Railway Cambodia (RRC)

ការចេញដំណើរពេលព្រឹក (សម្រាប់ខ្សែភ្នំពេញ ទៅ ខេត្តព្រះសីហនុ) ចាប់ផ្ដើមពីស្ថានីយយស្ម័យានរាជធានីភ្នំពេញម៉ោង ០៧:០០ ទៅដល់ស្ថានីយតាកែវម៉ោង ០៩:០០ ទៅដល់ស្ថានីយកំពតម៉ោង ១២:០០ និងទៅដល់ស្ថានីយចុងក្រោយគឺស្ថានីយព្រះសីហនុម៉ោង ១៥:០០

ការចេញដំណើរពេលព្រឹក (សម្រាប់ខ្សែខេត្តព្រះសីហនុ ទៅ ភ្នំពេញ) ចាប់ផ្ដើមពីស្ថានីយ

ព្រះសីហនុម៉ោង ០៧:០០ ទៅដល់ស្ថានីយកំពតម៉ោង ០៩:០០ ទៅដល់ស្ថានីយតាកែវម៉ោង ១២:០០ និងទៅដល់ស្ថានីយចុងក្រោយគឺស្ថានីយយស្ម័យានរាជធានីភ្នំពេញម៉ោង ១៤:០០

ការចេញដំណើរពេលរសៀល (សម្រាប់ខ្សែភ្នំពេញ ទៅ ខេត្តព្រះសីហនុ) ចាប់ផ្តើមពីស្ថានីយយស្ម័យានរាជធានីភ្នំពេញម៉ោង ១៦:០០ ទៅដល់ស្ថានីយតាកែវម៉ោង ១៨:០០ ទៅដល់ស្ថានីយកំពតម៉ោង ២០:៣០ និងទៅដល់ស្ថានីយចុងក្រោយគឺស្ថានីយព្រះសីហនុម៉ោង ២២:៣០

ការចេញដំណើរពេលរសៀល (សម្រាប់ខ្សែខេត្តព្រះសីហនុ ទៅ ភ្នំពេញ) ចាប់ផ្តើមពីស្ថានីយព្រះសីហនុម៉ោង ១៦:០០ ទៅដល់ស្ថានីយកំពតម៉ោង ១៨:០០ ទៅដល់ស្ថានីយតាកែវម៉ោង ២៣:៣០ និងទៅដល់ស្ថានីយចុងក្រោយគឺយស្ម័យានរាជធានីភ្នំពេញម៉ោង ២៣:៣០[58]។

**២.៣.២ ផ្លូវដែកភាគខាងជើង (ភ្នំពេញ-ប៉ោយប៉ែត)**

ផ្នែកដែលបានស្តារឡើងវិញប្រវែង ៤៨គីឡូម៉ែត្ររវាងស៊ីសុផុននិងប៉ោយប៉ែតដែលគ្រោងនឹងរៀបចំឡើងវិញនៅចុងឆ្នាំ ២០១៣ ដោយមានមូលនិធិពី ADB ប៉ុន្តែវាត្រូវបានពន្យាពេលដោយសារបញ្ហាថវិកា។ គិតត្រឹមថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១៤ មានតែ ៣២% នៃខ្សែផ្លូវខាងជើងត្រូវបានស្តារឡើងវិញ[59]។

ផ្លូវដែកពោធិ៍សាត់-ភ្នំពេញ មានប្រវែង ១៦៦គីឡូម៉ែត្រ ឆ្លងកាត់ខេត្តពោធិ៍សាត់-កំពង់ឆ្នាំង-កំពង់ស្ពឺ-កណ្តាល និងរាជធានីភ្នំពេញ។ កំណាត់ផ្លូវដែកពីពោធិ៍សាត់-ភ្នំពេញនេះ អាចបើកបរបានក្នុងល្បឿន៣០គីឡូម៉ែត្រក្នុងមួយម៉ោង ដោយមានស្ថានីយចំនួន២០ ជាអាទិ៍៖ ពោធិ៍សាត់-ទទឹងថ្ងៃ-កំរែង-បំណក់-ក្គុល-ក្រាំងស្គារ-រមាស-បារាំង-ក្រាំងល្វា-មានក-ត្បែងខ្ពស់-ដំណាក់ស្មាច់-ត្រាចទង-បាត់ដឹង-ទួលលៀប-ត្រពាំងត្នោត-សំរោង-ផ្លូវបំបែក-ពោធិ៍ចិនតុង-ភ្នំពេញ[60]។

ឯកឧត្តម ស៊ុន ចាន់ថុល រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូនបានបញ្ជាក់ថា "ផ្លូវដែកភាគខាងជើងនេះ គឺជាផ្លូវសេដ្ឋកិច្ចមួយដ៏មានសក្តានុពលក្នុងការដឹកជញ្ជូនផលិតផលនានារបស់ប្រជាពលរដ្ឋទៅកាន់ទីផ្សារក្នុងតំបន់ និងជាពិសេសទៅកាន់ប្រទេសថៃ។ ផ្លូវដែកនេះនឹងអនុញ្ញាតឲ្យប្រជាពលរដ្ឋដឹកទំនិញពីកម្ពុជាទៅថៃ និងដឹកទំនិញពីប្រទេសថៃមកកម្ពុជាវិញ ប្រកប

---

[58] Royal Railway Cambodia (RRC), ២០១៩

[59] Infrastructure and Regional Integration technical Working Group (IRITWG), "Overview of the Transport Infastructure Sector in the Kingdom of Cambodia, 5th edition, ឆ្នាំ ២០១៥

[60] អឹម រចនា, "ផ្លូវដែក ភ្នំពេញ-ប៉ោយប៉ែត ដំណើរការឡើងវិញ ក្រោយអាក់ខានអស់រយៈពេលជាង៤៥ឆ្នាំផ្លូវដែក ភ្នំពេញ-ប៉ោយប៉ែត ដំណើរការឡើងវិញ ក្រោយអាក់ខានអស់រយៈពេលជាង៤៥ឆ្នាំ", ថ្ងៃទី ០៤ កក្កដា ២០១៨, http://km.rfi.fr/cambodia/railway-pp-poipet-is-in-process-04-07-2018

ដោយភាពងាយស្រួល សុវត្ថិភាពខ្ពស់ និងចំណាយតិច”[61]។

ខណៈផ្លូវដែកនេះនឹងត្រូវតភ្ជាប់ជាមួយផ្លូវដែកនៃប្រទេសថៃ។ មួយផ្នែកទៀត ផ្លូវនេះបាន ចូលរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយការកកស្ទះចរាចរណ៍ គ្រោះថ្នាក់ចរាចរណ៍ និងផ្តល់ការប្រកួតប្រជែងក្នុងវិស័យដឹកជញ្ជូន។

កំណាត់ផ្លូវដែកពោធិ៍សាត់-ភ្នំពេញ ត្រូវបានស្តារឡើងវិញដោយប្រើប្រាស់ថវិកាជាតិចំនួន ២៣៤លានដុល្លារ ក្នុងគោលបំណងធ្វើយ៉ាងណាតភ្ជាប់ទាំងស្រុងផ្លូវដែកភាគខាងជើង (ភ្នំពេញ-ប៉ោយប៉ែត) ដែលមានប្រវែង ៣៨៥គីឡូម៉ែត្រ។ បន្ថែមពីលើនេះប្រវែងផ្លូវពីពោធិ៍សាត់ដល់ភ្នំពេញបានដាក់ដំណើរការនៅថ្ងៃទី ០៤ កក្កដា ឆ្នាំ២០១៨[62]។

កម្ពុជា និងថៃ មានកិច្ចព្រមព្រៀងជាគោលនៅក្នុងការតភ្ជាប់សេវាកម្មដឹកជញ្ជូនផ្លូវដែក រវាងប្រទេសទាំងពីរហើយ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ សេវាកម្មដឹកជញ្ជូនទាំងអ្នកដំណើរ និងទំនិញដោយប្រើផ្លូវដែករវាងប្រទេសទាំងពីរ នៅមិនទាន់បានដំណើរការនៅឡើយទេដោយ ទាមទារពេលវេលា និងការពិភាក្សាលម្អិតបន្ថែមទៀត។ តាមការចុះផ្សាយរបស់ AKP នាថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩ ដែលបានដកស្រង់សម្តីលោក វ៉ាស៊ីម សុរិយា អ្នកនាំពាក្យក្រសួងសាធារណការ និងដឹកជញ្ជូន “ការងារបន្ទាប់គឺខាងភាគីកម្ពុជា នឹងពិភាក្សាទៅលើការដឹកជញ្ជូនក្នុងស្រុក តាមរយៈក្រុមហ៊ុនទទួលបានសម្បទាន។ ការងារភ្ជាប់ផ្លូវដែកជាមួយថៃ គឺចប់សព្វគ្រប់ហើយ ប៉ុន្តែមិនមែនមានន័យថា យើងអាចធ្វើដំណើរជិះឆ្លងកាត់ ឬដឹកទំនិញព្រំដែនតាមរយៈរថភ្លើងបានភ្លាមនោះទេ។ ការពិភាក្សាលម្អិតទៅលើការដឹកជញ្ជូន ជាពិសេសពេលនេះ ផ្លូវដែកភាគខាងជើងនេះស្ថិតនៅក្រោមការគ្រប់គ្រងដោយក្រុមហ៊ុនទទួលសម្បទានពីរាជរដ្ឋាភិបាល”[63]។ កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩កន្លងទៅ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូនកម្ពុជា និងរដ្ឋមន្ត្រីដឹកជញ្ជូនថៃ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងប្រតិបត្តិការរួមគ្នាលើការដឹកជញ្ជូនតាមផ្លូវដែកឆ្លងកាត់ព្រំដែនកម្ពុជា-ថៃ និងចូលរួមក្នុងពិធីប្រគល់-ទទួល ក្បាលរថភ្លើង (DMU) ដែលជាអំណោយ

[61] អ៊ឹម រចនា, “ផ្លូវដែក ភ្នំពេញ-ប៉ោយប៉ែត ដំណើរការឡើងវិញ ក្រោយអាក់ខានអស់រយៈពេលជាង៤៥ឆ្នាំផ្លូវដែក ភ្នំពេញ-ប៉ោយប៉ែត ដំណើរការឡើងវិញ ក្រោយអាក់ខានអស់រយៈពេលជាង៤៥ឆ្នាំ”, ថ្ងៃទី ០៤ កក្កដា ២០១៨, http://km.rfi.fr/cambodia/railway-pp-poipet-is-in-process-04-07-2018

[62] Ibid

[63] ក្រសួងសាធារណការ និងដឹកជញ្ជូន, “ការដឹកជញ្ជូនឆ្លងកាត់ព្រំដែនកម្ពុជា-ថៃ មិនទាន់ដំណើរការឡើយ ទោះនាយករដ្ឋមន្ត្រីទាំង២ ជិះរថភ្លើងឆ្លងកាត់រួមគ្នាក៏ដោយ”,ថ្ងៃ ០៣ មិថុនា ២០១៩, http://www.mpwt.gov.kh/kh/post/7335

របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រថៃ ជូនរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ ពិធីចុះហត្ថលេខានេះ ធ្វើឡើងក្រោមអធិបតីភាពសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោក ប្រាយុទ្ធ ចាន់អូចា នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ។ បន្ទាប់ពីការចុះហត្ថលេខា នាយករដ្ឋមន្ត្រីទាំង២ ព្រមទាំងគណៈប្រតិភូ បានអញ្ជើញធ្វើដំណើររួមគ្នាតាមខ្សែរថភ្លើងពីស្ថានីយ បានក្លងលឹក នៃប្រទេសថៃ ឆ្ពោះមកកាន់ស្ថានីយរថភ្លើងប៉ោយប៉ែតនៃប្រទេសកម្ពុជា[64]។ ឯកឧត្តម ស៊ុន ចាន់ថុល ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូនបានលើកឡើងថា "ការតភ្ជាប់ផ្លូវដែកកម្ពុជា និងថៃ និងសម្រួលដល់ការដឹកទំនិញឆ្លងកាត់ព្រំដែន និងការធ្វើដំណើររបស់ប្រជាពលរដ្ឋ ជាពិសេសភ្ញៀវទេសចរពីកម្ពុជា ទៅទីក្រុងបាងកកប្រទេសថៃ។ មកពីភ្នំពេញ ឬពីក្រុងព្រះសីហនុ អាចឈប់ត្រង់ស្ថានីយនេះ (ស្ថានីយប៉ោយប៉ែត) រួចបន្តទៅដល់ទីក្រុងបាងកក។ ពីបាងកក ចង់ទៅម៉ាឡេស៊ីក៏បាន ទៅដល់សិង្ហបុរីក៏បាន សម្រាប់ដំណើរទេសចរណ៍ ដូច្នេះសំខាន់ណាស់ផ្លូវដែកនេះ"[65]។

តារាងទី ១០ ៖ បង្ហាញពីទិសដៅចេញដំណើរនៅខ្សែខាងជើង

| **ទិសដៅ** | **តម្លៃ** |
|---|---|
| ភ្នំពេញ-ប៉ោយប៉ែត / ប៉ោយប៉ែត-ភ្នំពេញ | មិនមាន |
| ភ្នំពេញ-បាត់ដឹង / បាត់ដឹង-ភ្នំពេញ | មិនមាន |
| ភ្នំពេញ-បាត់ដំបង / បាត់ដំបង-ភ្នំពេញ | មិនមាន |
| ភ្នំពេញ-សិរីសោភ័ណ / ស៊ីសុផុន-ភ្នំពេញ | មិនមាន |
| ភ្នំពេញ-ប៉ោយប៉ែត / ប៉ោយប៉ែត-ភ្នំពេញ | មិនមាន |
| ប៉ោយប៉ែត-ស៊ីសាផុន / ស៊ីសុផុន-ប៉ោយប៉ែត | មិនមាន |
| ប៉ោយប៉ែត-បាត់ដំបង / បាត់ដំបង-ប៉ោយប៉ែត | មិនមាន |
| ប៉ោយប៉ែត-ពោធិ៍សាត / ពោធិ៍សាត-ប៉ោយប៉ែត | មិនមាន |
| ប៉ោយប៉ែត-បាត់ដឹង/ បាត់ដឹង-ប៉ោយប៉ែត | មិនមាន |
| សិរីសោភ័ណ-បាត់ដំបង / បាត់ដំបង-សិរីសោភ័ណ | មិនមាន |

[64] ក្រសួងសាធារណការ និងដឹកជញ្ជូន, "ការដឹកជញ្ជូនឆ្លងកាត់ព្រំដែនកម្ពុជា-ថៃ មិនទាន់ដំណើរការឡើយ ទោះនាយករដ្ឋមន្ត្រីទាំង២ ជិះរថភ្លើងឆ្លងកាត់រួមគ្នាក៏ដោយ",ថ្ងៃ ០៣ មិថុនា ២០១៩, http://www.mpwt.gov.kh/kh/post/7335

[65] Ibid

| | |
|---|---|
| សិរីសោភ័ណ-ពោធិ៍សាត / ពោធិ៍សាត-ស៊ីសុផុន | មិនមាន |
| សិរីសោភ័ណ-បាត់ដឹង / បាត់ដឹង-ស៊ីសុផុន | មិនមាន |
| បាត់ដឹង-ពោធិ៍សាត / ពោធិ៍សាត-បាត់ដឹង | មិនមាន |
| បាត់ដឹង-សិរីសោភ័ណ / សិរីសោភ័ណ-បាត់ដឹង | មិនមាន |
| ពោធិ៍សាត-បាត់ដំបង / បាត់ដំបង-ពោធិ៍សាត់ | មិនមាន |
| ពោធិ៍សាត់-បាត់ដឹង / បាត់ដឹង-ពោធិ៍សាត់ | មិនមាន |

ប្រភពពី៖ ក្រសួងសាធារណការ និងដឹកជញ្ជូន

### ២.៣.២.២ តម្លៃផ្ញើយានជំនិះ

តារាងទី ១១ ៖ បង្ហាញពីតម្លៃដឹកជញ្ជូនយានជំនិះនៅខ្សែខាងជើង

| ប្រភេទយានយន្ត | តម្លៃ |
|---|---|
| រថយន្ត | ១៤ ដុល្លារ |
| ម៉ូតូ | ៥ ដុល្លារ |
| កង់ | ២ ដុល្លារ |
| ទំនិញ | មិនមាន |

ប្រភពពី៖ ក្រសួងសាធារណការ និងដឹកជញ្ជូន

### ២.៣.៣ និន្នន័យនៃការធ្វើប្រតិបត្តិការ ២០១៨

ផ្លូវដែកបច្ចុប្បន្នពោលគឺឆ្នាំ ២០១៨មានខ្សែរថភ្លើងធ្វើប្រតិបត្តិការចំនួន២ខ្សែ ខ្សែខាងជើង ខ្សែខាងត្បូងដែលបានប្រើប្រាស់ ក្បាលរថភ្លើងដឹកទំនិញ ចំនួន១៨គ្រឿង បានបន្ថែម៣គ្រឿងទៀត ដែលកាលពីឆ្នាំ២០១៧ មានតែ ១៥គ្រឿងប៉ុណ្ណោះ ក្នុងនោះក្បាលរថភ្លើងដឹកអ្នកដំណើរចំនួន ០១គ្រឿង និងទូរដឹកទំនិញ ២១២ទូ។ ជាក់ស្តែងក្នុងឆ្នាំ២០១៨ បរិមាណទំនិញដឹកជញ្ជូនតាមផ្លូវដែកសរុប ៩១៤,៨៧៩តោនក្នុងមួយឆ្នាំ និងបរិមាណកុងតឺន័រដែលដឹកដោយរថភ្លើង មានចំនួន ២៤,៨៦១គ្រឿង, ដឹកអ្នកដំណើរពីភ្នំពេញទៅក្រុងព្រះសីហនុមានចំនួន ២៨,៩៩៩នាក់ និង ភ្នំពេញ- ប៉ោយប៉ែតមានចំនួន ៧០,២៥១នាក់។ លើសពីនេះទៅទៀត ក្នុងឆ្នាំ២០១៨ មានចំនួន បុគ្គលិកបម្រើការក្នុងផ្នែកប្រតិបត្តិការណ៍មានចំនួន ២៤៨នាក់។ ទោះបីជាយ៉ាងណាយើងសង្កេតឃើញថាក្នុងឆ្នាំ២០១៨ជាឆ្នាំដែលផ្លូវដែករបស់ប្រទេសកម្ពុជាចាប់ផ្តើមមានប្រជាប្រិយភាពឡើងវិញក៏ពិតមែនប៉ុន្តែគេនៅតែសង្កេតឃើញថាវានៅមានចន្លោះខ្វះខាត ដោយក្នុងឆ្នាំ២០១៨ មាន

គ្រោះថ្នាក់ចរាចរណ៍ច្រើនរហូតទៅដល់១១ដង តួលេខនេះជាចំនួនច្រើនជាងគេបើគិតចាប់ពីឆ្នាំ ២០១០មកប៉ុន្តែករណីគ្រោះថ្នាក់ចរាចរណ៍នេះពុំបានធ្វើឲ្យមានការស្លាប់ ឬក៏រងរបួសនោះទេ[66]។

តារាងទី ១២ ៖ បង្ហាញពីទិន្នន័យទាក់ទងនឹងផ្លូវដែកកម្ពុជា

| លេខ | តំរុយ (Indicatior) | ២០១៨ |
|---|---|---|
| | សមត្ថភាព | |
| ១ | ខ្សែរថភ្លើង | ខ្សែជើង ខ្សែត្បូង |
| ២ | ចំនួនរថភ្លើង | |
| | ចំនួនក្បាលម៉ាស៊ីនដឹកទំនិញ | ១៨ |
| | ចំនួនក្បាលម៉ាស៊ីនដឹកអ្នកដំណើរ | ១ |
| | ចំនួនទូរថភ្លើង | ២១២ |
| | ការចរាចរណ៍ | |
| ៣ | បរិមាណដឹកទំនិញផ្លូវដែក (តោន) | ៩១៥,៨៧៩ |
| ៤ | បរិមាណកុងតឺន័រដឹកដោយរថភ្លើង | ២៤,៨៦១ |
| ៥ | បរិមាណដឹកអ្នកដំណើរ ភ្នំពេញ-ព្រះសីហនុ | ២៨៩,៩៩៩ |
| ៦ | បរិមាណដឹកអ្នកដំណើរ ភ្នំពេញ-ប៉ោតប៉ែត | ៧០,២៥១ |
| | ការប្រតិបត្តិការណ៍ | |
| ៧ | ចំនួនបុគ្គលិក(គិតតែប្រតិបត្តិការណ៍) | ២៤៨នាក់ |
| ៨ | ចំនួនគ្រោះថ្នាក់ | ១១ |
| ៩ | អ្នកស្លាប់ | 0 |
| ១០ | អ្នករបួស | 0 |

ប្រភពពី៖ ក្រសួងសាធារណការ និងដឹកជញ្ជូន

បន្ថែមពីលើនេះនៅក្នុងឆ្នាំ ២០១៨ ជាឆ្នាំដែលប្រវត្តិសាស្ត្រដែលគេឃើញថារីកចម្រើននូវវិស័យផ្លូវដែករបស់កម្ពុជា។ រដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុន RRC បានដាក់ឲ្យដំណើរការជាបណ្តោះអាសន្ននូវកំណាត់ផ្លូវរថភ្លើងនិងការដឹកជញ្ជូនអ្នកដំណើរពីរាជាយស្មយាន ឆ្ពោះទៅកាន់

[66] លិខិតលេខ ១១៧៨.ដ ចេញថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០១៩ របស់នាយកដ្ឋានផ្លូវដែកនៃក្រសួងសាធារណការ និងដឹកជញ្ជូន

អាកាសយានដ្ឋានអន្តរជាតិភ្នំពេញជាលើកដំបូង។ កំណាត់ផ្លូវរថភ្លើងដែលមានប្រវែងជាង ៩ គីឡូម៉ែត្រ គឺជាមុខមាត់ថ្មីមួយរបស់ទីក្រុងភ្នំពេញ ដើម្បីបញ្ចៀសការកកស្ទះចរាចរណ៍។ បន្ទាប់ពីកសាងរួចរាល់នៅក្នុងឆ្នាំ២០១៨ ហើយក៏មានការដាក់ដំណើរការជាបណ្តោះអាសន្នចាប់ពីថ្ងៃទី ១០ ខែមេសា រហូតដល់ថ្ងៃទី ១ ខែសីហា ឆ្នាំ២០១៨ ដោយមិនគិតថ្លៃ[67]។

ផ្លូវដែកនេះ ត្រូវបានរៀបចំឡើងជាប្រភេទ Tramway[68] សេវាដឹកជញ្ជូនតាមរថភ្លើងនេះចេញដំណើររៀងរាល់ ៣០នាទីម្តងដោយប្រើប្រាស់ថេរវេលាប្រមាណ ២២-២៥នាទី ពីស្ថានីយរាជាយស្ម័យានរាជធានីភ្នំពេញទៅកាន់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដោយឆ្លងកាត់កំណាត់ផ្លូវសហព័ន្ធរុស្ស៊ី ចូលអាកាសយានដ្ឋានអន្តរជាតិភ្នំពេញតែម្តង[69]។

ការដាក់ឲ្យដំណើរការផ្លូវរថភ្លើងនៅពេលនេះ គឺដើម្បីផ្តល់ជម្រើសក្នុងការធ្វើដំណើរជូនប្រជាពលរដ្ឋ កាត់បន្ថយការចំណាយថវិកា ពេលវេលា សុវត្ថិភាព គ្មានការរំខាន ព្រមទាំងរួមចំណែកកាត់បន្ថយការកកស្ទះ និងគ្រោះថ្នាក់ចរាចរណ៍ក្នុងរាជធានីភ្នំពេញ។ ក្នុងដំណាក់កាលដំបូងនេះ គេនឹងប្រើប្រាស់រថភ្លើងចំនួន ២គ្រឿងដែលមានស្រាប់ សម្រាប់ការផ្តល់សេវាដឹកជញ្ជូនអ្នកដំណើរទៅមក និងបានបន្ថែមក្បាលរថភ្លើងថ្មីចំនួន ៣គ្រឿងទៀតដែលបានបញ្ជាទិញមកពីប្រទេសម៉ិចស៊ីកូនៅដើមឆ្នាំ២០១៩[70]។

ផ្លូវដែកដែលរត់ក្នុងក្រុងភ្នំពេញ ពីស្ថានីយរាជាយស្ម័យានរាជធានីភ្នំពេញទៅកាន់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញនេះទទួលបានអ្នកដំណើរចំនួន ១១,៧០៩នាក់ក្នុងឆ្នាំ២០១៨[71]។

### ២.៤ ផែនការមេនិងយុទ្ធសាស្ត្រគោលការណ៍នៃការអភិវឌ្ឍន៍ផ្លូវដែក

សព្វថ្ងៃផ្លូវដែកត្រូវបានផ្តួចផ្តើមផែនការមេ ក្រោមជំនួយនិងកិច្ចសហប្រតិបត្តិការរបស់កូរ៉េ KOICA។ ជាការពិតណាស់ផែនការមេក្នុងការអភិវឌ្ឍផ្លូវដែករបស់កម្ពុជាជាមួយនឹងការបែងចែក

[67] វ៉ា សំណព្វ, "ផ្លូវរថភ្លើងទៅកាន់ព្រលានយន្តហោះជាលើកដំបូងត្រូវបានដាក់ឲ្យដំណើរការជាបណ្តោះអាសន្ន", ថ្ងៃទី ១០ មេសា ២០១៨, http://km.rfi.fr/cambodia/inauguration-traimway-ville-a%C3%A9roport-10-04-2018

[68] Tramway: ជាប្រភេទផ្លូវរថភ្លើងដែលបង្កប់លើផ្លូវថ្នល់ដែលអាចអនុញ្ញាតឲ្យយានយន្ត និងយានផ្សេងៗ អាចធ្វើដំណើរឆ្លងកាត់បាន

[69] វ៉ា សំណព្វ, "ផ្លូវរថភ្លើងទៅកាន់ព្រលានយន្តហោះជាលើកដំបូងត្រូវបានដាក់ឲ្យដំណើរការជាបណ្តោះអាសន្ន", ថ្ងៃទី ១០ មេសា ២០១៨, http://km.rfi.fr/cambodia/inauguration-traimway-ville-a%C3%A9roport-10-04-2018

[70] Ibid

[71] លិខិតលេខ ១១៧៨.ដ ចេញថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០១៩ របស់នាយកដ្ឋានផ្លូវដែកនៃក្រសួងសាធារណការ និងដឹកជញ្ជូន

ជា ៣ ដំណាក់កាលធំៗរួមមាន៖ ការអភិវឌ្ឍក្នុងពេលខ្លី (២០១៥-២០២០), ការអភិវឌ្ឍក្នុងពេលមធ្យម (២០២១-២០៣០) និងការអភិវឌ្ឍក្នុងពេលវែង (បន្ទាប់ពីឆ្នាំ ២០៣០)។

### ២.៤.១ ការអភិវឌ្ឍក្នុងពេលខ្លី ២០១៥-២០២០

គឺបែងចែកជាចំណុចសំខាន់ដូចជា[72]៖

- ខ្សែមេ D៖ សិក្សាពីគម្រោងក្នុងការបង្កើតផ្លូវដែកថ្មីភាគខាងកើតពោលគឺពីភ្នំពេញទៅឡុងនីញ ប្រទេសវៀតណាម
- ខ្សែមេ A ៖ ចូលរួមក្នុងការកសាងឡើងវិញនៅខ្សែភាគខាងជើង។

### ២.៤.២ ការអភិវឌ្ឍក្នុងពេលមធ្យម ២០២១-២០៣០

គឺបែងចែកជាចំណុចសំខាន់ដូចជា[73]៖

- ខ្សែមេ B ៖ សិក្សាពីគម្រោងអភិវឌ្ឍបន្ថែមទៅលើផ្លូវដែកខ្សែខាងត្បូងពីភ្នំពេញទៅក្រុងព្រះសីហនុ
- ខ្សែមេ C ៖ សិក្សាពីគម្រោងធ្វើផ្លូវដែកថ្មីពីភ្នំពេញទៅសៀមរាបដែលជាតំបន់ទេសចរណ៍សំខាន់របស់កម្ពុជា។

### ២.៤.៣ ការអភិវឌ្ឍក្នុងពេលវែងបន្ទាប់ពីឆ្នាំ ២០៣០

គឺបែងចែកជាចំណុចសំខាន់ដូចជា[74]៖

#### ២.៤.៣.១ ផ្លូវដែកល្បឿនលឿន

- ផ្លូវដែកខ្សែ A ដែលមានប្រវែង ៤០០គីឡូម៉ែត្រពីភ្នំពេញទៅប៉ោយប៉ែត ដល់ប្រទេសថៃ
- ផ្លូវដែកខ្សែ B ដែលមានប្រវែង ២៥៣គីឡូម៉ែត្រពីភ្នំពេញទៅក្រុងព្រះសីហនុ
- ផ្លូវដែកខ្សែ C ដែលមានប្រវែង ៣១៥ គីឡូម៉ែត្រពីស៊ីសុផុនទៅដល់ស្រុក ជើងព្រៃ ខេត្តកំពង់ចាម
- ផ្លូវដែកខ្សែ D ដែលមានប្រវែង ២៣៦ គីឡូម៉ែត្រពីវាំងចាស់នៅឧត្តុង្គទៅដល់ស្រុកស្ទួល ខេត្តកំពង់ចាម

[72] កិច្ចប្រជុំ ASEAN Railway CEO's Conference លើកទី ៣៦ ប្រទេសវៀតណាម, "Master Plan for Railway Network Development in Cambodia", ឆ្នាំ ២០១៤

[73] Ibid

[74] Ibid

- ខ្សែរមេ E គម្រោងក្នុងការអនុវត្តរយៈពេលវែងភ្ជាប់ផ្លូវដែកពីភ្នំពេញទៅប្រទេសឡាវ[75]។

### ២.៤.៣.២ តំបន់សក្តានុពល

- ខ្សែតំណាងលេខ ១ ដែលមានប្រវែង ៧៣គីឡូម៉ែត្រ ដោយភ្ជាប់ពីស្រុក ព្រៃជ្រុំ ទៅឧត្តរមានជ័យក្នុងតំបន់ដែលក្បែរប្រទេសថៃ
- ខ្សែតំណាងលេខ ២ មានប្រវែង ១៣៦គីឡូម៉ែត្រ ដែលក្នុងគោលបំណងដើម្បីអភិវឌ្ឍតំបន់ដែលមានធនធានរ៉ែតភ្ជាប់ទៅខេត្តព្រះវិហារ
- ខ្សែតំណាងលេខ ៣ មានប្រវែង ១៥៨គីឡូម៉ែត្រ ធ្វើឡើងក្នុងគោលបំណងលើកតំកើនសេដ្ឋកិច្ចនៅក្នុងភូមិឃុំស្រុក ដោយអភិវឌ្ឍនូវការធ្វើរបបកសិកម្មដើម្បីយកផលិតផលមកលក់ និងតំបន់ទេសចរណ៍នៅតាមតំបន់នោះ
- ខ្សែតំណាងលេខ ៤ ប្រវែង ១១៤គីឡូម៉ែត្រ ដើម្បីផ្សព្វផ្សាយនូវតំបន់អភិវឌ្ឍ ដោយធ្វើឲ្យកាន់តែល្អនូវមធ្យោបាយដឹកជញ្ជូនសំរាប់ប្រជាជន
- ខ្សែតំណាងលេខ ៥ ប្រវែង ១០៦គីឡូម៉ែត្រ ធ្វើឡើងក្នុងគោលបំណងលើកតំកើនសេដ្ឋកិច្ចនៅក្នុងភូមិឃុំស្រុក ដោយអភិវឌ្ឍនូវការធ្វើរបបកសិកម្មដើម្បីយកផលិតផលមកលក់ និងតំបន់ទេសចរណ៍នៅតាមតំបន់នោះ
- ខ្សែតំណាងលេខ ៦ ប្រវែង ៧១គីឡូម៉ែត្រ ពិចារណាការអភិវឌ្ឍ និងខ្សែភ្ជាប់ទំនាក់ទំនងកម្ពុជា - ថៃ ពោលគឺពីបាត់ដំបងទៅជាយដែនប្រទេសថៃ
- ខ្សែតំណាងលេខ ៧ ប្រវែង ២៥០គីឡូម៉ែត្រ ពិចារណាលើការកែលម្អទេសចរណ៍ ផែនការអភិវឌ្ឍន៍នៃកំពង់ផែ និងឧស្សាហកម្មឲ្យកាន់តែងាយស្រួលដោយដឹកជញ្ជូនតាមរយៈរថភ្លើងដោយមិនចាំបាច់ឆ្លងកាត់ទីក្រុងភ្នំពេញ
- ខ្សែតំណាងលេខ ៨ ប្រវែង ១៣៤គីឡូម៉ែត្រ ដើម្បីជម្រុញការអភិវឌ្ឍន៍ដោយភ្ជាប់ទៅកំពង់ផែថ្មី, តំបន់ឧស្សាហកម្ម និងដឹកជញ្ជូន[76]។

### ២.៤.៣.៣ ផ្លូវឧស្សាហកម្ម

- ពីឧត្តរមានជ័យទៅព្រះវិហារដែលមានប្រវែង ១៨១គីឡូម៉ែត្រ

[75] កិច្ចប្រជុំ ASEAN Railway CEO's Conference លើកទី ៣៦ ប្រទេសវៀតណាម, "Master Plan for Railway Network Development in Cambodia", ឆ្នាំ ២០១៤

[76] Ibid

- ពីព្រះវិហារទៅស្ទឹងត្រែងដែលមានប្រវែង ១១៣ គីឡូម៉ែត្រ
- ពីមណ្ឌលគីរីទៅរតនគិរីដែលមានប្រវែង ១៥១ គីឡូម៉ែត្រ
- ពីស្រុកកំពង់សិលាខេត្តព្រះសីហនុទៅវាលរេញ ដែលមានប្រវែង ៤៨គីឡូម៉ែត្រ[77]។

#### ២.៤.៣.៤ ផ្លូវដែកទៅកាន់ព្រលានយន្តហោះ និងកំពង់ផែ

- ពីទីក្រុងភ្នំពេញទៅព្រលានយន្តហោះថ្មីដែលមានប្រវែង ៤២ គីឡូម៉ែត្រ
- ខ្សែព្រលានយន្តហោះកំពង់ឆ្នាំងដែលមានប្រវែង ២១ គីឡូម៉ែត្រ
- ភ្ជាប់ទៅកំពង់ផែកំពតដែលមានប្រវែង ៤ គីឡូម៉ែត្រ
- សៀមរាបទៅព្រលានយន្តហោះថ្មីដែលមានប្រវែង ៣ គីឡូម៉ែត្រ[78]។

### ២.៤.៤ ស្តង់ដាផ្លូវដែក

តារាងទី ១៣ ៖ បង្ហាញពីទិន្នន័យស្តង់ដាផ្លូវដែកកម្ពុជា

| | ផ្លូវដែកធម្មតា | ផ្លូវដែកល្បឿនលឿន |
|---|---|---|
| រង្វាស់ | ១.០០០មីលីម៉ែត្រ | ១.៤៣៥មីលីម៉ែត្រ |
| ល្បឿនសរុប | ១២០គីឡូម៉ែត្រ/ម៉ោង | ៣៥០គីឡូម៉ែត្រ/ម៉ោង |
| ជម្រាលអតិបរមា | ១០% | ២៥% |
| គន្លង់អតិបរមា | ៩០មីលីម៉ែត្រ | ១៦០មីលីម៉ែត្រ |

ប្រភពពី៖ កិច្ចប្រជុំ ASEAN railway CEO's Conference លើកទី ៣៦ នៅប្រទេសវៀតណាម

ក្នុងតារាងខាងលើបង្ហាញពីស្តង់ដាផ្លូវដែកក្នុងគម្រោងផែនការលើ ផ្លូវដែករបស់កម្ពុជានឹងត្រូវការរង្វាស់ (ទទឹង) ផ្លូវដែក ១,០០០មីលីម៉ែត្រ, ជម្រាលអតិបរិមា ១០% និងហើយគន្លង់អតិបរិមា ៩០មីលីម៉ែត្រ បើផ្លូវដែកកម្ពុជាអាចធ្វើបានដូចខាងលើនោះដំណើរការផ្លូវដែកនឹងកាន់តែល្អ និងរលូន ហើយអាចបើកបរក្នុងល្បឿនធម្មតា១២០គីឡូម៉ែត្រក្នុងម៉ោង។ ចំណែកឯស្តង់ផ្លូវដែកល្បឿនលឿនរបស់កម្ពុជាត្រូវការស្តង់ដារង្វាស់(ទទឹង)ផ្លូវដែក ១,៤៣៥ មីលីម៉ែត្រ ជម្រាលអតិបរិមា ២៥% និងគន្លង់អតិបរិមា ១៦០មីលីម៉ែត្រ ហើយបើកម្ពុជាអាចធ្វើបានដូចខាងលើនោះដំណើរការផ្លូវដែកនឹងកាន់តែល្អ និងរលូន ហើយអាចបើកបរក្នុងល្បឿន ៣៥០គីឡូម៉ែត្រក្នុងមួយម៉ោង។

---

[77] Infrastructure and Regional Integration Technical Working Group (IRITWG), "Overview of the Transport Infastructure Sector in the Kingdom of Cambodia, 5th edition, ឆ្នាំ ២០១៥

[78] Ibid

### ២.៤.៥ បញ្ហាប្រឈមចម្បងសម្រាប់គម្រោងផែនការមេ

ទោះបីជាកម្ពុជាបានព្យាយាមធ្វើឲ្យផ្លូវដែកមានដំណើរការបានល្អ និងអាចមានប្រយោជន៍សេដ្ឋកិច្ចយ៉ាងច្រើនចំពោះកម្ពុជាក៏ដោយ តែនឹងមានបញ្ហាចម្បងៗមួយចំនួនក្នុងការអនុវត្តផែនការមេ នោះគឺ[79]៖

- បញ្ហាទី ១៖ ភាពមិនស្មើគ្នានៃការអភិវឌ្ឍក្នុងចំណោមតំបន់ដែលធ្វើផ្លូវដែក
- បញ្ហាទី ២៖ កង្វះខាតថវិការបស់ជាតិ
- បញ្ហាទី ៣៖ ភាពមិនស្មើគ្នាក្នុងដំណើរសេដ្ឋកិច្ចរវាងកម្ពុជានិងប្រទេសជិតខាង
- បញ្ហាទី ៤៖ ភាពខុសគ្នាក្នុងការអភិវឌ្ឍនៅតំបន់ដែលមានសក្តានុពល
- បញ្ហាទី៥៖ ភាពក្រីក្រនៅតាមតំបន់ជនបទ
- បញ្ហាទី៦៖ តម្រូវការកសាងផ្លូវដែកដែលបាត់បង់ និងតភ្ជាប់ខ្សែថ្មី
- បញ្ហាទី៧៖ កង្វះខាតនូវប្រព័ន្ធផ្លូវដែកចាស់ៗច្រើន។

បញ្ហាទាំង៧ ដូចខាងលើនេះដែលធ្វើឲ្យកម្ពុជាជួបនឹងការលំបាកក្នុងការអនុវត្តនូវផែនការមេដែលបានសិក្សាដោយកូរ៉េ KOICA។

### ២.៤.៦ ដំណោះស្រាយសម្រាប់គម្រោងផែនការមេ

ទោះបីជាផ្លូវដែកកម្ពុជាអាចនឹងជួបនូវបញ្ហាជាច្រើនដែលបានចេញពីការសិក្សាវិភាគ និងរំពឹងទុកដែលធ្វើគម្រោងផែនការមេពិបាកក៏ដោយ រដ្ឋាភិបាលកម្ពុជាបានព្យាយាមស្វែងរកដំណោះស្រាយដោយដាក់ចេញនូវ៤ គោលដៅ និង ៧យុទ្ធសាស្ត្រសំខាន់ៗដូចជា[80]៖

តារាងទី១៤៖ បង្ហាញពីដំណោះស្រាយគោលដៅ និងយុទ្ធសាស្ត្រនៃផែនការមេ

| គោលដៅ | យុទ្ធសាស្ត្រ |
|---|---|
| ១. អភិវឌ្ឍផ្លូវដែកដើម្បីលើកកម្ពស់សេដ្ឋកិច្ចជាតិ | ១. ការអភិវឌ្ឍន៍ និងពិពិធកម្មកំណើនសេដ្ឋកិច្ច<br>២. ធ្វើសមាហរណកម្មជាតិ |
| ២. អភិវឌ្ឍផ្លូវដែកក្នុងតំបន់ដើម្បីការឆ្ពោះទៅមុខ និងលុបបំបាត់ភាពក្រីក្រ | ៣. លើកកម្ពស់សេដ្ឋកិច្ចជាតិ<br>៤. ធ្វើការអភិវឌ្ឍសេដ្ឋកិច្ចក្នុងតំបន់ដើម្បីលុបបំបាត់ភាពក្រីក្រ |

[79] កិច្ចប្រជុំ ASEAN Railway CEO's Conference លើកទី ៣៦ ប្រទេសវៀតណាម, "Master Plan for Railway Network Development in Cambodia", ឆ្នាំ ២០១៤

[80] Ibid

| | |
|---|---|
| ៣. រឹតចំណងសហប្រតិបត្តិការអន្តរជាតិ និងកំណើនសេដ្ឋកិច្ច | ៦. បង្កើតនូវប្រព័ន្ធអន្តរជាតិ<br>៧. ប្រព័ន្ធរថភ្លើងមានល្បឿនលឿន |
| ៤. បង្កើតប្រព័ន្ធចរាចរណ៍ដែលចំណាយតិច និងប្រសិទ្ធភាពខ្ពស់ | ៥. បង្កើនប្រព័ន្ធអន្តរជាតិ |

ប្រភពពី៖ Infrastructure and Regional Inegration Technical Working Group, "Overview of the Transport Infrastructure Sector In the kingdom of Cambodia, 5th Edition ឆ្នាំ ២០១៥

- គោលដៅ ១ អភិវឌ្ឍផ្លូវដែកដើម្បីលើកកម្ពស់សេដ្ឋកិច្ចជាតិ ដើម្បីសម្រេចនូវគោលដៅទី ១ រដ្ឋាភិបាលកម្ពុជាបានដាក់ចេញ យុទ្ធសាស្ត្រ ២
    - យុទ្ធសាស្ត្រទី ១ ការអភិវឌ្ឍន៍ និងពិពិធកម្មកំណើនសេដ្ឋកិច្ច
    - យុទ្ធសាស្ត្រទី ២ ធ្វើសមាហរណកម្មជាតិ
- គោលដៅទី ២ អភិវឌ្ឍផ្លូវដែកក្នុងតំបន់ដើម្បីការឆ្ពោះទៅមុខ និងលុបបំបាត់ភាពក្រីក្រ ដើម្បីសម្រេចនូវគោលដៅទី ២ បានដាក់ចេញ យុទ្ធសាស្ត្រ ២
    - យុទ្ធសាស្ត្រទី ៣ លើកកម្ពស់សេដ្ឋកិច្ចជាតិ
    - យុទ្ធសាស្ត្រទី ៤ ធ្វើការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងតំបន់ដើម្បីលុបបំបាត់ភាពក្រីក្រ
- គោលដៅទី ៣ រឹតចំណងសហប្រតិបត្តិការអន្តរជាតិ និងកំណើនសេដ្ឋកិច្ច ដើម្បីសម្រេចនូវគោលដៅទី ៣ រដ្ឋាភិបាលកម្ពុជាបានដាក់ចេញ យុទ្ធសាស្ត្រ ២
    - យុទ្ធសាស្ត្រទី ៦ បង្កើតនូវប្រព័ន្ធអន្តរជាតិ
    - យុទ្ធសាស្ត្រទី ៧ ប្រព័ន្ធរថភ្លើងមានល្បឿនលឿន
- គោលដៅទី ៤ បង្កើតប្រព័ន្ធចរាចរណ៍ដែលចំណាយតិច និងប្រសិទ្ធិភាពខ្ពស់ ដើម្បីសម្រេចនូវគោលដៅទី ៤ រដ្ឋាភិបាលកម្ពុជាបានដាក់ចេញ យុទ្ធសាស្ត្រ ១
    - យុទ្ធសាស្ត្រទី ៥ បង្កើនប្រព័ន្ធអន្តរជាតិ។

## ២.៥ អត្ថប្រយោជន៍សេដ្ឋកិច្ចពីវិស័យដឹកជញ្ជូនផ្លូវដែកក្រោយពីសម្រេចផែនការមេ

តម្លៃសរុបនៃគម្រោងនេះ នឹងមានឥទ្ធិពលវិជ្ជមានទៅដល់សេដ្ឋកិច្ចជាតិដូចជា ករណីដឹកជញ្ជូនទំនិញ ដើម្បីកាត់បន្ថយចំណាយថ្លៃដើម, ដឹកជញ្ជូនអ្នកដំណើរ, កាត់បន្ថយថវិកាជាតិដែល

ចំណាយទៅលើការជួសជុលផ្លូវជាតិ និងសន្សំពេលវេលា។ គម្រោងអភិវឌ្ឍនេះមានអត្ថប្រយោជន៍ដ៏មានវិសាលភាពដែលវារួមចំណែកដោយផ្ទាល់ ឬដោយប្រយោលចំពោះការកាត់បន្ថយភាពក្រីក្រ។

ផលប្រយោជន៍ដល់អ្នកក្រីក្រពីគម្រោងនេះអាចត្រូវបានគេរំពឹងថា នឹងរួមមាន[81]៖

អត្ថប្រយោជន៍ផ្ទាល់ ៖ ដោយកើតចេញពីការកាត់បន្ថយការចំណាយលើការដឹកជញ្ជូនផ្ទាល់ខ្លួន, អាចបង្កើតឱកាសការងារនៃការប្រកបអាជីវកម្មផ្សេងៗដល់ប្រជាជនដែលរស់នៅក្បែរតំបន់អភិវឌ្ឍផ្លូវដែក, សន្សំសំចៃពេលវេលានៃការធ្វើដំណើររបស់ប្រជាជនទូទៅ, សន្សំសំចៃការចំណាយថ្លៃធ្វើដំណើរដែលមានតម្លៃថ្លៃ និងកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍។ គេប៉ាន់ប្រមាណថាអត្ថប្រយោជន៍សេដ្ឋកិច្ចដ៏សំខាន់នឹងបានមកពីការផ្តល់សេវាដឹកជញ្ជូនអ្នកដំណើរនៅលើផ្លូវដែកដែលនិងផលប្រយោជន៍ដ៏ច្រើនលើសលប់ដល់រដ្ឋាភិបាល (ដែលប៉ាន់ប្រមាណ 0,៦ លានដុល្លារអាមេរិក ក្នុងឆ្នាំដំបូងនៃប្រតិបត្តិការ ហើយក្នុងឆ្នាំ២០៣០ អាចកើនដល់ ៣លានដុល្លារ ក្នុងមួយឆ្នាំបើសិនជាការអនុវត្តប្រកបដោយប្រសិទ្ធភាព)

អត្ថប្រយោជន៍ដោយប្រយោល ៖ ធ្វើឲ្យចំណាយដឹកជញ្ជូនថ្លៃដើមទាប (ទាំងរបស់របរប្រើប្រាស់ប្រចាំថ្ងៃ និង ម្ហូបអាហាររបស់ប្រជាជន)។

### ២.៥.១ ការប៉ាន់ប្រមាណនៃការសន្សំការប្រើប្រាស់ប្រេង

ការជួសជុលផ្លូវរថភ្លើងនៅកម្ពុជាអាចមានផលប្រយោជន៍ និងសន្សំសំចៃច្រើនដែលបានកើតចេញក្រោយពីការជួសជុលផ្លូវរថភ្លើងបន្ទាប់ពីគម្រោងផែនការមេ ពោលគឺបើអាចធ្វើឲ្យផ្លូវរថភ្លើងមានកំណើនឡើងវិញគឺអាចមានសមត្ថភាពបង្វែរពីការដឹកជញ្ជូនតាមផ្លូវជាតិទៅដឹកជញ្ជូនតាមរយៈផ្លូវដែកដែលសន្សំសំចៃប្រេងសាំងបានចំនួន ០.២៩៣៦ ដុល្លារក្នុងមួយលីត្រ និងអាចសន្សំសំចៃចំណាយនៃការប្រើប្រាស់ប្រេងសាំងរហូតដល់ ៥៩៥ លានដុល្លារនៅក្នុងឆ្នាំ២០៣០ ប្រសិនបើគម្រោងផែនការមេអនុវត្តបានជោគជ័យ[82]។

### ២.៥.២ ការប៉ាន់ប្រមាណនៃការសន្សំក្នុងចំណាយលើការថែទាំផ្លូវ

ការលុបបំបាត់ចរាចរណ៍យានយន្តធុនធ្ងន់ពីបណ្តាញផ្លូវជាតិ បន្ទាប់ពីការស្តារឡើងវិញនៃផ្លូវដែកត្រូវបានរំពឹងថានឹងមានឥទ្ធិពល លើការកាត់បន្ថយការចំណាយលើការថែទាំផ្លូវ ដែល

[81] ADB Report, "Cambodia: Preparing the Greater Mekong Subregion: Rehabilitition of the railway Cambodia", ឆ្នាំ ២០០៦

[82] Ibid

យោងទៅតាមការសិក្សាពី JICA បានបង្ហាញឲ្យឃើញថា បើផ្លូវរថភ្លើងនៅកម្ពុជាអាចដំណើរបានយ៉ាងល្អដូចគម្រោងផែនការមេ គេអាចសន្សំលុយពីការជួសជុលផ្លូវជាតិ (ប្រមាណ ៣៩លានដុល្លារនៅក្នុងឆ្នាំ២០៣០) ដែលបណ្តាលមកពីការខូចខាតដោយរថយន្តធុនធ្ងន់ដឹកជញ្ជូននៅលើផ្លូវជាតិ[83]។

### ២.៥.៣ ការប៉ាន់ស្មាននៃការសន្សំពីគ្រោះថ្នាក់ចរាចរណ៍

គ្រោះថ្នាក់ចរាចរណ៍ត្រូវបានកើតឡើងយ៉ាងច្រើននៅតាមបណ្តាយផ្លូវជាតិលេខ ៣ ផ្លូវជាតិលេខ ៤ និងផ្លូវជាតិលេខ៥។ នៅក្នុងន័យនេះ គេសង្កេតឃើញថាគ្រោះថ្នាក់ចរាចរណ៍ទាំងនេះបណ្តាលឲ្យមានការខាតបង់ថវិកាជាតិ, ខូចខាតទ្រព្យសម្បត្តិសាធារណៈ (ផ្លូវថ្នល់ បង្គោលភ្លើង របាំងផ្លូវ) និងបាត់បង់ផលិតភាពជាតិ។ ផ្លូវជាតិលេខ៣ មានគ្រោះថ្នាក់ចំនួន ១៥៩ករណី ក្នុងនោះមានអ្នកបាត់បង់ជីវិតភ្លាមៗនៅកន្លែងកើតហេតុ ៣០នាក់, របួសធ្ងន់ចំនួន ១៤៧នាក់, របួសស្រាលចំនួន ១៧៨នាក់។ ផ្លូវជាតិលេខ ៤ គ្រោះថ្នាក់ចរាចរណ៍មាន ២៩២ករណី ក្នុងនោះមានអ្នកដែលស្លាប់ភ្លាមៗនៅកន្លែងកើតហេតុ ៩៩នាក់, អ្នកដែលរបួសធ្ងន់ចំនួន ១៨២នាក់, អ្នករបួសស្រាល ២៧៥ នាក់។ ផ្លូវជាតិលេខ ៥ មានគ្រោះថ្នាក់ចរាចរណ៍ ៧៦៣ករណី មានអ្នកស្លាប់១៨០នាក់, អ្នករបួសធ្ងន់ ៦៣៧នាក់, និងអ្នករបួសស្រាល ៧៥៩នាក់[84]។

តារាងទី ១៥ ៖ បង្ហាញពីគ្រោះថ្នាក់ និងការខាតបង់

| ផ្លូវជាតិលេខ ៣ | ចំនួនតួលេខ |
|---|---|
| គ្រោះថ្នាក់ (ករណី) | ១៥៩ |
| ស្លាប់ (នាក់) | ៣០ |
| ស្ថានភាពធ្ងន់ធ្ងរ (នាក់) | ១៤៧ |
| ស្ថានភាពស្រាល (នាក់) | ១៧៨ |
| ផ្លូវជាតិលេខ ៤ | ចំនួនតួលេខ |
| គ្រោះថ្នាក់ (ករណី) | ២៩២ |
| ស្លាប់ (នាក់) | ៩៩ |
| ស្ថានភាពធ្ងន់ធ្ងរ (នាក់) | ១៨២ |
| ស្ថានភាពស្រាល (នាក់) | ២៧៥ |

[83] ADB Report, "Cambodia: Preparing the Greater Mekong Subregion: Rehabilitition of the railway Cambodia", ឆ្នាំ ២០០៦

[84] Ibid

| ផ្លូវជាតិលេខ ៥ | ចំនួនតួលេខ |
|---|---|
| គ្រោះថ្នាក់ (ករណី) | ៧៦៣ |
| ស្លាប់ (នាក់) | ១៨០ |
| ស្ថានភាពធ្ងន់ធ្ងរ (នាក់) | ៦៣៧ |
| ស្ថានភាពស្រាល (នាក់) | ៧៩៨ |

ប្រភពពី៖ ADB technical Assistance Consultant′s Report, Cambodia: Preparing the Greater Mekong Sub region: Rehabilitation of the Railway in Cambodia, ឆ្នាំ ២០០៦

មានន័យថាក្នុងគ្រោះថ្នាក់ចរាចរណ៍ទាំងនោះអាចនឹងខាតបង់នូវសេដ្ឋកិច្ចជាតិយ៉ាងច្រើន ប្រសិនបើករណីស្លាប់ វានឹងបណ្តាលឲ្យខូតខាតទ្រព្យសម្បត្តិជាតិរហូត ១,១៣២ដុល្លារក្នុងមួយករណី, ចំណាយរដ្ឋបាល ២,១៧២ដុល្លារ ក្នុងមួយករណី សរុបករណីដែលស្លាប់ខាតបង់ថវិកា ៣,៣០៤ដុល្លារក្នុងមួយករណី (ករណីស្លាប់ភ្លាមៗនៅកន្លែងកើតហេតុ)។ ប្រសិនបើករណីគ្រោះថ្នាក់ចរាចរណ៍ដែលបណ្តាលឲ្យមានរបួសធ្ងន់អាចធ្វើឲ្យខូចខាតទ្រព្យសម្បត្តិជាតិ ២,៧៧៧ដុល្លារក្នុងមួយករណី, ចំណាយរដ្ឋបាល ១,៦២៧ដុល្លារក្នុងមួយករណីសរុបករណីដែលមានរបួសធ្ងន់អាចនឹងចំណាយ ៤,៤០៤ដុល្លារក្នុងមួយករណី។ ករណីដែលគ្រោះថ្នាក់មានរបួសស្រាលអាចធ្វើឲ្យខាតបង់ទ្រព្យសម្បត្តិជាតិ ៥៤៥ដុល្លារក្នុងមួយករណី, ចំណាយរដ្ឋបាល ៥៤៣ដុល្លារក្នុងមួយករណី សរុបករណីដែលមានរបួសស្រាលអាចនឹងចំណាយ ១,០៨៨។

តារាងទី ១៦ ៖ បង្ហាញពីចំនួននៃការខាតបង់ពីគ្រោះថ្នាក់ចរាចរណ៍

| សង្ខេប | ស្លាប់ | ស្ថានភាពធ្ងន់ធ្ងរ | ស្ថានភាពស្រាល |
|---|---|---|---|
| ទ្រព្យសម្បត្តិជាតិ | ១,១៣២ | ២,៧៧៧ | ៥៤៥ |
| ចំណាយរដ្ឋបាល | ២,១៧២ | ១,៦២៩ | ៥៤៣ |
| សរុប | ៣,៣០៤ | ៤៤០៦ | ១,០៨៨ |

ប្រភពពី៖ ADB technical Assistance Consultant′s Report, Cambodia: Preparing the Greater Mekong Sub region: Rehabilitation of the Railway in Cambodia

ដូចនេះការធ្វើដំណើរតាមផ្លូវជាតិអាចបណ្តាលឲ្យជួបករណីគ្រោះថ្នាក់ចរាចរណ៍ដោយយថាហេតុជាញឹកញាប់បាន ព្រមទាំងអាចធ្វើឲ្យខាតបង់នូវសេដ្ឋកិច្ច និងថវិកាជាតិជាច្រើន។

# ជំពូកទី ៣

# ការវិភាគវិស័យដឹកជញ្ជូនផ្លូវដែក

## ៣.១ វិភាគទៅលើទិន្នន័យដឹកជញ្ជូនទំនិញ និងអ្នកដំណើរតាមផ្លូវដែក

### ៣.១.១ វិភាគលើទិន្នន័យដឹកជញ្ជូនទំនិញ

យោងតាមប្រភពមកពី RRC ទំហំនៃការដឹកជញ្ជូនតាំងពីឆ្នាំ២០១០ក្រោយពេលដែលផ្លូវដែកខ្សែខាងត្បូងប្រគល់ទៅឲ្យក្រុមហ៊ុនឯកជនគ្រប់គ្រងមានការដឹកជញ្ជូនកើនឡើង ដែលមានន័យថានៅក្នុងឆ្នាំ២០១០ ទំហំនៃការដឹកជញ្ជូនទំនិញមានត្រឹមតែ ១៦,២៨៨តោន។ រហូតមកដល់ឆ្នាំ ២០១៨ តាមរបាយការណ៍ដែលក្រុមហ៊ុន RRC បានផ្តល់ជូនទៅនាយកដ្ឋានផ្លូវដែកនៃក្រសួងសារណការ និងដឹកជញ្ជូន តាមរយៈលិខិតលេខ ១១៧ផជ ចុះនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ បានឲ្យឃើញថា នៅក្នុងឆ្នាំ២០១៧ ទំហំនៃការដឹកជញ្ជូនទំនិញមាន ៤១៩,១០៦ តោន ដោយប្រើកុងតឺន័រ ២៧,០០៨ គ្រឿង និងបានថយចុះទំហំនៃការដឹកជញ្ជូនបន្តិចប៉ុណ្ណោះក្នុងឆ្នាំ២០១៨ គឺបានត្រឹម ៤១៤,៨៧៩តោន ដោយប្រើកុងតឺន័រ ២៤,៨៦១គ្រឿង[85]។ ខាងក្រោមនេះជាតារាងបង្ហាញពីទំហំនៃការដឹកជញ្ជូននៅខ្សែភាគខាងត្បូង (ភ្នំពេញទៅក្រុងព្រះសីហនុ) រយៈពេល ៨ឆ្នាំចុងក្រោយ។

តារាងទី ១៧ ៖ បង្ហាញពីទំហំនៃការដឹកជញ្ជូនសរុបតាមឆ្នាំនីមួយៗ (២០១០-២០១៨)

| ឆ្នាំ | ទំនិញ(តោន) | ចំនួនកុងទីន័រ (គ្រឿង) |
|---|---|---|
| **២០១០** | ១៦.២៨៨ | 0 |
| **២០១១** | ២០.១២៤ | 0 |
| **២០១២** | ៨.៩៦៨ | 0 |
| **២០១៣** | ៥៤.២០៥ | ៤.៤០០ |
| **២០១៤** | ១៩៦.២៩០ | ១១.៦៦០ |
| **២០១៥** | ២៩៥.០៧៦ | ២០.០៩៧ |
| **២០១៦** | ៣២៥.៨៥១ | ២១.២៩៥ |
| **២០១៧** | ៤១៩.១០៦ | ២៧.០០៨ |
| **២០១៨** | ៤១៤.៩៨៧ | ២៤.៨៦១ |

ប្រភពពី៖ លិខិតលេខ ១១៧ផ.ដ ចេញថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០១៩ របស់នាយកដ្ឋានផ្លូវដែកនៃក្រសួងសាធារណការ និងដឹកជញ្ជូន

[85] លិខិតលេខ ១១៧ផ.ដ ចេញថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០១៩ របស់នាយកដ្ឋានផ្លូវដែកនៃក្រសួងសាធារណការ និងដឹកជញ្ជូន

ក្រាហ្វិកទី ៣ ៖ បង្ហាញពីទិន្នន័យនៃការដឹកជញ្ជូនសរុបតាមឆ្នាំនីមួយៗ (២០១០-២០១៨)




ប្រភពពី៖ លិខិតលេខ ១១៧៨.ដ ចេញថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០១៩ របស់នាយកដ្ឋានផ្លូវដែក នៃក្រសួងសាធារណការ និងដឹកជញ្ជូន

តាមរយៈក្រាហ្វិកបង្ហាញឲ្យឃើញថា ពីមួយឆ្នាំទៅមួយឆ្នាំការដឹកជញ្ជូនពោលគឺនៅឆ្នាំ ២០១០ មានទំហំនៃការដឹកជញ្ជូនត្រឹមតែ ១% ប៉ុណ្ណោះដែលគិតជាតួលេខស្មើនឹង ១៦,២៨៤តោន។ នៅឆ្នាំ២០១១ ក៏គេពុំសង្កេតឃើញទំហំនៃការដឹកជញ្ជូនមានកំណើនកើនឡើងខ្លាំងនោះទេ គឺមានប្រមាណ ១% ដូចគ្នាកាលពីឆ្នាំ២០១០ ប៉ុន្តែទិន្នន័យនេះបើគិតជាចំនួនតួលេខមានការកើនឡើងត្រឹមតែជាង ២០,១២៨តោន (កើនឡើង ៣ពាន់តោនប៉ុណ្ណោះ)។ ក្នុងឆ្នាំ២០១២ មានការថមថយមកវិញត្រឹម ៨,៩៦៨តោនប៉ុណ្ណោះ ដែលនៅតែស្ថិតក្នុងរង្វង់ ១% ដូចឆ្នាំ ២០១០ និងឆ្នាំ ២០១១ ដែរ។ គេបានសង្កេតឃើញទំហំដឹកជញ្ជូនហាក់មានការកើនឡើងវិញនៅឆ្នាំ២០១៣ គឺកើនស្ទើរតែជាង២ដងនៃឆ្នាំចាស់ៗ បើគិតជាតួលេខមានប្រមាណ ៥៤,២០៥តោន ដែលស្មើនឹងការកើនឡើង ៣%។ នៅក្នុងឆ្នាំ ២០១៤ ទំហំនៃការដឹកជញ្ជូនកើនតែឡើងរហូតដល់ ៩% ដែលស្មើនឹង ១៤៦,២៩០តោន។ ទំហំនៃការដឹកជញ្ជូននេះនៅតែបន្តមានការកើនឡើងនៅក្នុងឆ្នាំ ២០១៥ ដែលកើនឡើងចំនួន ១៧% ស្មើនឹង ២៩៥,០៧៦តោន។ ក្នុងឆ្នាំ ២០១៦ ទំហំនៃការដឹកជញ្ជូនកាន់តែកើនឡើងថែមទៀតរហូតដល់ ១៩% ស្មើនឹង ៣២៥,៨៥១តោន។ ទំហំនៃការដឹកជញ្ជូនកើនឡើងកាន់តែច្រើនឡើងនៅក្នុងឆ្នាំ ២០១៧ រហូតដល់ ២៥% ដែលស្មើនឹង ៤១៩,១០៦តោន។

ប៉ុន្តែតួលេខបានធ្លាក់ចុះមកវិញបន្តិចបន្តិចប៉ុណ្ណោះ (ត្រឹម ១%) ដែលមានន័យថាធ្លាក់ចុះមកត្រឹម ២៤% នៅក្នុងឆ្នាំ ២០១៨ ដែលស្មើនឹង ៩១៤,៩៨៧តោន។

### ៣.១.២ វិភាគលើទិន្នន័យដឹកជញ្ជូនអ្នកដំណើរតាមផ្លូវដែក

ក្រាហ្វិកទី ៤ ៖ បង្ហាញពីទិន្នន័យអ្នកធ្វើដំណើរតាមរថភ្លើងសរុប ឆ្នាំ ២០១៧ និង ២០១៨




ប្រភពពី៖ លិខិតលេខ ១១៧៨.ដ ចេញថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០១៩ របស់នាយកដ្ឋានផ្លូវដែកនៃក្រសួងសាធារណការ និងដឹកជញ្ជូន

នៅអំឡុងឆ្នាំ ២០១០ ដល់ ២០១៦ ពុំមានសេវាកម្មដឹកអ្នកដំណើរឡើយនៅខ្សែខាងត្បូង។ សម្រាប់ខ្សែខាងជើងក៏ពុំមានសេវាកម្មដឹកអ្នកដំណើរដូចខ្សែខាងត្បូងដែរនៅអំឡុងឆ្នាំ ២០១០ ដល់ ២០១៧[86]។

សម្រាប់សេវាកម្មដឹកអ្នកដំណើរ គេសង្កេតឃើញថាទើបតែធ្វើការដឹកអ្នកដំណើរឡើងវិញនៅខ្សែភាគខាងត្បូងនៅក្នុងឆ្នាំ២០១៧ ដែលទទួលបានអ្នកដំណើររហូតដល់ ៣១,១១៦ នាក់ ខណ:ដែលខ្សែរថភ្លើងនៅភាគខាងជើងពុំទាន់បានបើកឲ្យដំណើរការឡើយទាំងសម្រាប់ដឹកអ្នកដំណើរ និងសម្រាប់ដឹកទំនិញក្នុងឆ្នាំ២០១៧[87]។ លុះរហូតដល់ឆ្នាំ២០១៨ ទើបខ្សែរថភ្លើងភាគខាងជើងបានបើកឲ្យដំណើរការដឹកអ្នកដំណើរតែប៉ុណ្ណោះ មិនទាន់អាចដឹកទំនិញឆ្លងកាត់នោះទេ។

[86] លិខិតលេខ ១១៧៨.ដ ចេញថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០១៩ របស់នាយកដ្ឋានផ្លូវដែកនៃក្រសួងសាធារណការ និងដឹកជញ្ជូន

[87] Ibid

ក្នុងឆ្នាំ២០១៨ ខ្សែខាងជើងបានទទួលអ្នកដំណើរច្រើនជាងសឹងតែ ២ដងនៃខ្សែខាងត្បូង ជាអាទិ៍ ខ្សែខាងជើងទទួលអ្នកដំណើររហូតដល់ ៧០,២៥១នាក់ក្នុងឆ្នាំ២០១៨ ខណៈដែលខ្សែខាងត្បូង ទទួលបានត្រឹមតែ ២៨,៩៩៩នាក់ប៉ុណ្ណោះក្នុងឆ្នាំដូចគ្នា[88]។ មានមូលហេតុជាច្រើនដែលធ្វើឲ្យខ្សែ ខាងជើងមានអ្នកដំណើរច្រើន គឺដោយសារនៅក្នុងអំឡុងពេលដាក់ដំណើរការបណ្តោះអាសន្ន ក្នុងខែឧសភា ឆ្នាំ២០១៨ ក្រសួងសារធារណការ និងដឹកជញ្ជូនសហការណ៍ជាមួយក្រុមហ៊ុន RRC បានអនុញ្ញាតឲ្យប្រជាពលរដ្ឋធ្វើដំណើរពីភ្នំពេញទៅប៉ោយប៉ែត ដោយមិនគិតថ្លៃរហូត ដល់ចុងខែធ្នូ ឆ្នាំ២០១៨។ ម្យ៉ាងវិញដោយសារខ្សែខាងជើងនេះបានរត់កាត់ខេត្តជាច្រើន រួមមាន ខេត្តកំពង់ឆ្នាំង, ពោធិ៍សាត់, បាត់ដំបង, បន្ទាយមានជ័យ, និងប៉ោយប៉ែត។ ទោះបីជាខ្សែនេះបាន ចំណាយពេលវេលាច្រើនបន្តិចក៏ដោយ ប៉ុន្តែមានប្រជាជនមួយចំនួននៅតែចង់សាកល្បង។

### ៣.២ វិភាគទៅលើលទ្ធផលនៃការស្រង់មតិ

យោងទៅតាមការធ្វើកម្រងសំណួរដែលសាកសួរមតិប្រជាជនជិះរថភ្លើង ក្នុងនោះមាន ចំនួនមនុស្ស ៤០នាក់ដែល មានបុរសចំនួន ១៥នាក់ (ស្មើនឹង៣៧.៥ភាគរយ) និងនារីចំនួន ២៥ នាក់ (ស្មើនឹង ៦២.៥ភាគរយ) ដែលបានធ្វើដំណើរតាមរយៈរថភ្លើងពីភ្នំពេញ ទៅខេត្តកំពត។

#### ៣.២.១ អ្នកដំណើរតាមរថភ្លើង

ក្រាហ្វិកទី ៥ ៖ បង្ហាញពីទិន្នន័យអាយុអ្នកដំណើរ




សរុបចំនួនអ្នកដំណើរមាន ៤០នាក់ (បុរសមាន ១៥នាក់, នារីមាន ២៥នាក់)
ប្រភពពី៖ Survey (២០១៩)

[88] លិខិតលេខ ១១៧៨.ដ ចេញថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០១៩ របស់នាយកដ្ឋានផ្លូវដែកនៃក្រសួងសាធារណការ និង ដឹកជញ្ជូន

បន្ថែមពីលើនេះទៅទៀតអ្នកដែលជិះរថភ្លើងភាគច្រើនសុទ្ធសឹងតែជាយុវជន ពុំសូវមានមនុស្សវ័យកណ្តាល ឬមនុស្សចាស់ទេ ជាអាទិ៍ក្នុងចំណោមអ្នកដំណើរ ៤០នាក់ មនុស្សដែលមាន

- អាយុក្រោម ១៨ឆ្នាំចំនួន ៥ភាគរយ ស្មើនឹង ២នាក់
- អាយុចន្លោះពី ១៨ ទៅ ២៣ឆ្នាំ មានរហូតដល់ ៥៥ភាគរយ ដែលស្មើនឹង ២២នាក់
- អាយុចន្លោះ ២៤ ដល់ ៣០ មាន ៣០ភាគរយ ស្មើនឹង ១២នាក់
- អាយុចន្លោះពី ៣១ ទៅ ៣៥ឆ្នាំ មានតែ ១នាក់ស្មើនឹង ២.៥ភាគរយ
- អាយុចន្លោះ ពី ៣៦ ទៅ ៤០ឆ្នាំ មានត្រឹមតែ ៥ ភាគរយ ស្មើនឹង ២នាក់ប៉ុណ្ណោះ
- អាយុចន្លោះ ៤១ ទៅ ៤៥ឆ្នាំ មាន១នាក់ប៉ុណ្ណោះ ដែលស្មើនឹង ២.៥ភាគរយ។

### ៣.២.២ មុខរបររបស់អ្នកដំណើរ

ក្រាហ្វិកទី ៦ ៖ បង្ហាញពីទិន្នន័យមុខរបររបស់អ្នកដំណើរ




ប្រភពពី៖ Survey, (២០១៩)

តាមការសម្រង់មតិនេះបានបង្ហាញឲ្យឃើញទៀតថា ភាគច្រើនមនុស្សដែលសម្រេចចិត្តជិះរថភ្លើងមានមុខរបរជាសិស្ស និស្សិតមានរហូតដល់ ២៣នាក់ដែលចំនួននេះស្មើនឹង ៥៧.៥ ភាគរយ។ អ្នកដែលបម្រើការក្នុងស្ថាប័ន ឬក្រុមហ៊ុនឯកជនមានចំនួន ៧នាក់ ស្មើនឹង ១៧.៥ ភាគរយ។ មន្ត្រីរាជការដែលបានជិះរថភ្លើងមានចំនួន ៦នាក់ ស្មើនឹង១៥ភាគរយ។ ចុងក្រោយគឺអ្នកដែលប្រកបរបរជាអ្នកលក់ដូរមាន ៤នាក់ ស្មើនឹង ១០ភាគរយ។

### ៣.២.៣ ការធ្វើដំណើរការតាមរដូវកាល

ក្រាហ្វិកទី ៧ ៖ បង្ហាញពីទិន្នន័យរដូវកាលដែលអ្នកដំណើរចូលចិត្តជិះរថភ្លើង




ប្រភពពី៖ Survey, (២០១៩)

យោងតាមក្រាហ្វិកខាងលើ ចំនួនអ្នកដំណើរដែលចូលចិត្តជិះរថភ្លើងក្នុងអំឡុងពេលបុណ្យចូលឆ្នាំប្រពៃណីខ្មែរមានតែ ៥ភាគរយស្មើនឹង ២នាក់ប៉ុណ្ណោះ។ ប៉ុន្តែអ្នកដំណើរដែលមានចំណង់ចំណូលជិះរថភ្លើងគឺមានភាគច្រើនក្នុងអំឡុងពេលចុងសប្តាហ៍ដែលតួលេខរហូតដល់ទៅ ៩៥ភាគរយ។

### ៣.២.៤ មូលហេតុដែលអ្នកដំណើរជ្រើសរើសយកការជិះរថភ្លើង

ក្រាហ្វិកទី ៨ ៖ បង្ហាញពីទិន្នន័យមូលហេតុដែលអ្នកដំណើរជ្រើសរើសជិះរថភ្លើង




ប្រភពពី៖ Survey, (២០១៩)

យោងតាមទិន្នន័យមូលហេតុនៃអ្នកដំណើរជ្រើសរើសយកការជិះរថភ្លើងដែលចំនួនច្រើនជាងគេគឺជិះរថភ្លើងដើម្បីដំណើរកម្សាន្តដែលទិន្នន័យមាន ២៣នាក់ ស្មើនឹង ៥៧.៥ភាគរយ។ អ្នកដំណើរដែលគិតថាការជិះរថភ្លើងដើម្បីសុវត្ថិភាពមានចំនួន ៨នាក់ ស្មើនឹង ២០ភាគរយ។ អ្នកដំណើរដែលជ្រើសរើសយកការជិះរថភ្លើងដោយសារគ្មានការកកស្ទះចរាចរណ៍មានចំនួន ៧នាក់ ស្មើនឹង ១៧.៥ភាគរយ។ មានអ្នកដំណើរម្នាក់ជ្រើសរើសយកការជិះរថភ្លើង ដោយសារហេតុផលផ្សេង។ ប៉ុន្តែមិនមានអ្នកដំណើរណាដែលជ្រើសរើសយកការជិះរថភ្លើង ដោយសារតម្លៃសមរម្យ ឬងាយស្រួលក្នុងការដឹកជញ្ជូនទំនិញឡើយ។

### ៣.២.៥ មូលហេតុដែលអ្នកដំណើរមិនជ្រើសរើសយកការជិះរថភ្លើង

ក្រាហ្វិកទី ៩ ៖ បង្ហាញពីទិន្នន័យមូលហេតុដែលអ្នកដំណើរមិនជ្រើសរើសយកការជិះរថភ្លើង




ប្រភពពី៖ Survey, (២០១៩)

មូលហេតុមួយចំនួនដែលប្រជាជនមិនជ្រើសរើសការជិះរថភ្លើងនោះ គឺអ្នកដំណើរ ៦នាក់ ស្មើនឹង ១៥ភាគរយគិតថារថភ្លើងមានល្បឿនយឺត។ មួយចំនួនពុំសូវបានទទួលនូវព័ត៌មាននៃការធ្វើដំណើររបស់រថភ្លើងដែលក្នុងនោះមានប្រហែល ១០នាក់ ស្មើនឹង ២៥ភាគរយ។ មូលហេតុផ្សេងទៀតគឺដោយសារតែពួកគេយល់ថា រថភ្លើងមានស្ថានីយចំណតឆ្ងាយពីផ្ទះរបស់ពួកគេពេក ដែលជាហេតុធ្វើឲ្យពួកគេពិបាកក្នុងការធ្វើដំណើរមកស្ថានីយដើម្បីជិះរថភ្លើង ដោយក្នុងចំណោម ៤០នាក់នោះមាន ៩នាក់ ស្មើនឹង ២២.៥ភាគរយ។ មានអ្នកដំណើរម្នាក់មិនចង់ជិះរថភ្លើង

ដោយសារទទួលបានព័ត៌មានមិនល្អពីរថភ្លើងពីមុនមក ប៉ុន្តែមិនមានអ្នកដំណើរណាគិតថាសំបុត្រមានតម្លៃថ្លៃឡើយ។

### ៣.២.៦ ការវិភាគលើទំនាក់ទំនង

ក. ទំនាក់ទំនងរវាងភេទ និងមូលហេតុនៃការជិះរថភ្លើង

តារាងទី ១៨ ៖ បង្ហាញពីទំនាក់ទំនងរវាងភេទ និងមូលហេតុនៃការជិះរថភ្លើង

| | | | ដំណើរកម្សាន្ត | សុវត្ថិភាព | គ្មានការកកស្ទះ | ផ្សេងពីនេះ | សរុប |
|---|---|---|---|---|---|---|---|
| ភេទ | បុរស | ចំនួន | ៩ | ៥ | ១ | ០ | ១៥ |
| | | ភាគរយ | ៦០% | ៣៣% | ៦.៧% | ០% | ១០០% |
| | នារី | ចំនួន | ១៤ | ៣ | ៦ | ១ | ២៤ |
| | | ភាគរយ | ៥៨.៣% | ១២.៥% | ២៥% | ៤.២% | ១០០% |
| | សរុប | ចំនួន | ២៣ | ៨ | ៧ | ១ | ៣៩ |
| | | ភាគរយ | ៥៩% | ២០% | ១៧.៩% | ២.៦% | ១០០% |

ប្រភពពី៖ Survey, (២០១៩)

ទំនាក់ទំនងរវាងភេទ និងមូលហេតុមួយចំនួនដែលក្នុងនោះអ្នកដែលជ្រើសរើសការជិះរថភ្លើងដែលមាន៖

- ភេទប្រុស
  - ជ្រើសរើសការជិះរថភ្លើងក្នុងគោលបំណងដើម្បីដំណើរកម្សាន្តមានចំនួន ៩នាក់ ដែលស្មើនឹង ៦០ភាគរយ ក្នុងចំណោមមនុស្សប្រុសទាំងអស់ ១៥នាក់ ស្មើនឹង ១០០ភាគរយ។
  - ការជ្រើសរើសជិះរថភ្លើងរបស់មនុស្សប្រុសដោយសារតែយល់ថា ការជិះរថភ្លើងអាចមានសុវត្ថិភាពមានចំនួន ៥នាក់ ដែលស្មើនឹង ៣៣.៣ភាគរយ។
  - មនុស្សភេទប្រុសមានតែម្នាក់ប៉ុណ្ណោះ ដែលបានជ្រើសរើសការជិះរថភ្លើងដោយសារដែលយល់ថាគ្មានការកកស្ទះចរាចរណ៍។
- ភេទស្រី
  - អ្នកដែលជិះរថភ្លើងក្នុងគោលបំណងដើម្បីដំណើរកម្សាន្តរបស់មនុស្សស្រីមានត្រឹមតែ ៥៨.៣ភាគរយ មានន័យថាក្នុងចំណោមមនុស្សស្រីទាំងអស់ ២៤នាក់ មានមនុស្សស្រី១៤នាក់ជិះរថភ្លើងដោយសារតែដំណើរកម្សាន្ត

